00432533

D97/15/1

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 18 / 01 / 2010
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Tuy

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ ៣៧)

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ០: សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ"ដីកាសម្រេច អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩**

---

ដាក់ដោយ៖

**មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS, QC

ផ្ញើជូន៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម ន័យ ធុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 19 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

00432534

D97/15/1

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ)

---

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង**

# មាតិកា

I. សេចក្តីផ្តើម និង ការទាមទារ....................................................................៤

II. បទដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍....................................................................៧

III. មូលហេតុទី១ នៃបណ្តឹងឧទ្ធរណ៍: ការសម្គាល់មិនគ្រប់គ្រាន់នៃភាពអាចអនុវត្តបាន នៃ JCE III....................................................................៨

៣.១ សេចក្តីផ្តើម.................................................................... ៨

៣.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ....................................................................៩

៣.៣ សំណើ....................................................................៩

៣.៤ សេចក្តីសន្និដ្ឋាន....................................................................១៣

IV. មូលហេតុទី២ នៃបណ្តឹងឧទ្ធរណ៍-ការខកខានមិនបានផ្តល់មូលហេតុចំពោះការច្រានចោលអំណះអំណាងរបស់មេធាវីការពារក្តីប្រឆាំងនឹងរឿងក្តី Tadic.................១៣

៤.១ សេចក្តីផ្តើម....................................................................១៣

៤.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ....................................................................១៤

៤.៣ សំណើ....................................................................១៤

៤.៤ សេចក្តីសន្និដ្ឋាន....................................................................១៥

V. មូលហេតុទី៣ នៃបណ្តឹងឧទ្ធរណ៍-ការខកខានដោះស្រាយលើអំណះអំណាងរបស់មេធាវីការពារក្តីដែលថា JCE I និង JCE III មិនបានសម្គាល់ឱ្យបានសមស្រប.....១៦

៥.១ សេចក្តីផ្តើម....................................................................១៦

៥.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ....................................................................១៦

៥.៣ សំណើ....................................................................១៧

៥.៤ សេចក្តីសន្និដ្ឋាន....................................................................១៨

VI. មូលហេតុទី៤ នៃបណ្តឹងឧទ្ធរណ៍: ការខកខានក្នុងការដោះស្រាយលើឧត្តិករណ៍របស់មេធាវីការពារក្តី: JCE II និង JCE III មិនអាចអនុវត្តបានទេ........................

00432536




៦.១ សេចក្ដីផ្ដើម......១៩

៦.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ......១៩

៦.៣ សំណើ......២០

៦.៤ សេចក្ដីសន្និដ្ឋាន......២១

VII. មូលហេតុទី៥ នៃបណ្ដឹងឧទ្ធរណ៍: កំហុសផ្នែកច្បាប់: ពុំមានយុត្តាធិការលើ JCE II និង JCE III- ពុំមានមូលដ្ឋានក្នុងច្បាប់ជាតិ......២១

៧.១ សេចក្ដីផ្ដើម......២១

៧.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ......២១

៧.៣ សំណើ......២១

៧.៤ សេចក្ដីសន្និដ្ឋាន......២២

VIII. មូលហេតុទី៦ នៃបណ្ដឹងឧទ្ធរណ៍: ការខកខានមិនបានវិភាគលើទម្លាប់អន្តរជាតិ ដែលជាមូលដ្ឋានសម្រាប់ JCE......២៣

៨.១ សេចក្ដីផ្ដើម......២៣

៨.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ......២៣

៨.៣ សំណើ......២៣

៨.៤ សេចក្ដីសន្និដ្ឋាន......២៥

IX. មូលហេតុទី៧ នៃបណ្ដឹងឧទ្ធរណ៍-អវត្តមានមូលដ្ឋាននៃទម្លាប់អន្តរជាតិសម្រាប់ JCE

៩.១ សេចក្ដីផ្ដើម......២៥

៩.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ......២៦

៩.៣ សំណើ......២៦

៩.៤ សេចក្ដីសន្និដ្ឋាន......៣១

X. សំណើសុំសវនាការផ្ទាល់មាត់......៣១

XI. សំណូមពរ......៣២

## I. សេចក្ដីផ្ដើម និង ការទាមទារ

1. នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានដាក់“ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម” (ដីកាសម្រេច)[1]។ មេធាវីការពារក្ដីសូមដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះដោយស្នើឱ្យអង្គបុរេជំនុំជម្រះ (អបជ) ច្រានចោលដីកាសម្រេចនេះទុកជាឥតបានការ ហើយស្នើឱ្យ អបជ យល់ឃើញថា អ.វ.ត.ក មិនមានយុត្តាធិការលើសហឧក្រិដ្ឋកម្មរួមនេះ (JCE) ដែលជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងរឿងក្ដីលេខ ០០២[2]។ បើមិនដូច្នោះទេ មេធាវីការពារក្ដីស្នើសុំឱ្យ អបជ យល់ឃើញថា អ.វ.ត.ក មិនមានយុត្តាធិការក្នុងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នោះទេនៅក្នុងរឿងក្ដីនេះ បន្ថែមពីនេះ មេធាវីការពារក្ដីយល់ឃើញថា សហព្រះរាជអាជ្ញាមិនបានសម្អាងឱ្យបានគ្រប់គ្រាន់អំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និង ទម្រង់ទី៣ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ អាស្រ័យហេតុនេះ ទម្រង់នៃការទទួលខុសត្រូវដែលហៅថាសហឧក្រិដ្ឋកម្មរួមនេះមិនអាចយកមកអនុវត្តបានទេនៅក្នុងសំណុំរឿងលេខ ០០២។

2. ទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមមានភាពចម្រូងចម្រាស់ខ្លាំង។ សំណេរវិភាគស៊ីជម្រៅមួយចំនួនច្រើនបានសរសេរឡើងដែរនៅក្នុងរយៈពេលប៉ុណ្ណានឆ្នាំនេះ ចាប់តាំងពីទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមមានចាប់ផ្ដើមកកើតនៅក្នុងឆ្នាំ១៩៩៣មកម្លេះ[3]។ សូម្បីចៅក្រមមួយរូបនៅសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់

---

[1] ក.ស.ច.ស. ដីកាសម្រេចលើពាក្យសុំឱ្យដាក់ទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌ ហៅថា សហកម្មឧក្រិដ្ឋកម្មរួម ឱ្យអនុវត្តនៅចំពោះមុខអ.វ.ត.ក ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D97/13។

[2] មេធាវីការពារក្ដីដាក់លិខិតជូនទាន់ពេលមួយជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍។ សូមមើល កំណត់ហេតុបណ្ដឹងឧទ្ធរណ៍ អៀង ធិរិទ្ធ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D97/15។

[3] ជាអាទិ៍ សូមមើលអត្ថបទរបស់ A.M. Danner និង J.S. Martinez ស្ដីអំពី “ភារុទ្ធភាពតាមការចូលរួម៖ សហកម្មឧក្រិដ្ឋរួម ការទទួលខុសត្រូវក្នុងនាមជាមេបញ្ជាការ និងការវិវឌ្ឍន៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ” បោះពុម្ពផ្សាយខែមិនា ឆ្នាំ២០០៤។ ក្នុងចំណោមឯកសារដទៃទៀត សូមមើលផងដែរនូវឯកសាររបស់ K. Hamdorf ស្ដីអំពី “ទស្សនៈទាននៃសហកម្មឧក្រិដ្ឋកម្មរួម និងទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌជាតិ សម្រាប់ភាគីនៅក្នុងឧក្រិដ្ឋកម្មណាមួយ” បោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្តិយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៥ (ឆ្នាំ២០០៧) ទំព័រ ២០៨-២២៦ ឯកសាររបស់ J.D. Ohlin “បញ្ហាទស្សនៈទានចំនួនបីទាក់ទងទៅនឹងលទ្ធិសហកម្មឧក្រិដ្ឋកម្មរួម” បោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្តិច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ៥ (ឆ្នាំ២០០៧) ទំព័រ ៦៩-៨០ ឯកសាររបស់ E. van Sliedrecht ស្ដីពី “សហកម្មឧក្រិដ្ឋកម្មរួមជាមធ្យោបាយដើម្បីដាក់ទោសបុគ្គលសម្រាប់អំពើប្រល័យពូជសាស្ត្រ” ចេញផ្សាយក្នុងព្រឹត្តិបត្តិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ៥ (ឆ្នាំ២០០៧) ទំព័រ ១៨៤-២០៧ ឯកសាររបស់ G. Sluiter ស្ដីពី “ពិរុទ្ធភាពតាមរយៈការចូលរួម៖ សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងការកាត់សេចក្ដី”

អតីតប្រទេសយូហ្គោស្លាវី (ICTY) ក៏បានសុំឱ្យលុបចោលនូវទម្រង់នៃការទទួលខុសត្រូវមួយនេះ ដែលចៅក្រម Lindholm នៅសាលាក្តីនេះ បានចេញនូវគំនិតជំទាស់មួយដាច់ដោយឡែកលើផ្នែកមួយចំនួននៅក្នុងសាលក្រមក្នុងរឿងក្តី *Blagoje Simic*។ ចៅក្រមរូបនេះបានដកខ្លួនចេញពីទស្សនទានទូទៅនៃសហឧក្រិដ្ឋកម្មរួម[4]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក៏បានអនុវត្តវិធីសាស្ត្រមួយខុសពី ICTY ផងដែរ នៅពេលបកស្រាយទម្រង់នៃការទទួលខុសត្រូវទាំងនេះ។ និយាយឱ្យច្បាស់ជាងនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិបានឈរលើជំហរមួយផ្សេងចំពោះទ្រឹស្តីសហឧក្រិដ្ឋកម្មរួម។ នៅក្នុងរឿងក្តី *Lubanga* អង្គបុរេជំនុំជម្រះនៃ ICC បានបដិសេធការស្នើសុំដោយត្រង់ៗមួយពីមេធាវីរបស់ជនរងគ្រោះមួយរូប ដែលបានសុំឱ្យបញ្ចូល JCE នៅក្នុងបទចោទទាំងឡាយដើម្បីដាក់បន្ទុកលើជនជាប់ចោទ[5]។ Weigend បានលើកបញ្ហានេះឡើងដើម្បីពន្យល់អំពីសេចក្តីសម្រេចរបស់ ICC នៅក្នុងរឿងក្តី *Lubanga*ៈ

> ប៉ុន្តែ អង្គជំនុំជម្រះក៏បានលើកឡើងនូវលក្ខខណ្ឌព្យួរទុកសំខាន់ៗចំពោះការទទួលស្គាល់ JCE ថាជាទម្រង់នៃការទទួលខុសត្រូវមួយ"ចំបង" អនុលោមតាមលក្ខន្តិកៈនៃ ICC។ អង្គជំនុំជម្រះបានភ្ជាប់ JCE ទៅនឹង"វិធីសាស្ត្រអត្តនោម័ត"ចំពោះការបែងចែករវាងចារី និង ជនដែលបានចូលរួម។ វាជាវិធីសាស្ត្រមួយដែលទាញបង្វែរការផ្តោតពីកម្រិតចូលរួមចំណែកដោយសត្យានុម័តទៅរក"ស្ថានភាពផ្លូវចិត្ត ដែលការចូលរួមចំណែកនៅក្នុងឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង"[6]។

---

ចេញផ្សាយក្នុងព្រឹត្តិបត្រ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៦៧ ឆ្នាំ២០០៧។ សូមមើលផងដែរ ឯកសាររបស់ A. Cassese ស្តីពី "ដែនកំណត់សមស្របនៃការទទួលខុសត្រូវបុគ្គលក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម" ចេញផ្សាយក្នុងព្រឹត្តិបត្រ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៥ ឆ្នាំ២០០៧ ទំព័រ ១០៩-១៣៣ ទំព័រ ១១៤-១២៣។ លោក William Schabas កំណត់សហកម្មឧក្រិដ្ឋកម្មរួមថាជា "ដំណោះស្រាយវេទមន្ត" របស់រដ្ឋអាជ្ញា។ សូមមើលផងដែរ ឯកសាររបស់ A.M. Danner & J.S. Martinez ស្តីពី "ភាពទុទ្ធភាពតាមការចូលរួម៖ សហកម្មឧក្រិដ្ឋរួម ការទទួលខុសត្រូវក្នុងនាមជាមេបញ្ជាការ និងការវិវឌ្ឍន៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" បោះពុម្ពផ្សាយខែមិនា ឆ្នាំ២០០៤ ទំព័រ៦០។

[4] រឿងក្តី រដ្ឋអាជ្ញា តទល់ជាមួយ *Blagoje Simic* យោបល់ដោយឡែងនិងជំទាស់ជាផ្នែករបស់ចៅក្រម Per-Johan Lindholm ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ ក្នុងសំណុំរឿងលេខ IT-95-9-T កថាខណ្ឌទី២។

[5] រឿងក្តី រដ្ឋអាជ្ញា តទល់ជាមួយ *Lubanga* សេចក្តីសម្រេចបញ្ជាក់ពីបទចោទ របស់អង្គជំនុំបុរេជម្រះ ១ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ សំណុំរឿងលេខ ICC 01/04-01/06។

[6] ឯកសាររបស់ T. Weigend ស្តីពី "ចេតនា កំហុសច្បាប់ និងការប្រព្រឹត្តរួម នៅក្នុងសេចក្តីសម្រេចរឿងក្តីរបស់ *Lubanga* បញ្ជាក់ពីបទចោទ" ចេញផ្សាយក្នុងព្រឹត្តិបត្រ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៦ ឆ្នាំ២០០៨ ទំព័រ ៤៧១-៤៧៨ ត្រង់ទំព័រ ៤៧៨។

00432539



3. សូម្បី Antonio Cassese ដែលជាចៅក្រមប្រឹក្សាមួយរូបនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះសាលាកំពូលក្នុងរឿងក្តី *Tadic* ដែលបានបង្កើតទ្រឹស្តីនេះឡើង បានទទួលស្គាល់ថា ទ្រឹស្តីនេះស្ថិតនៅក្នុងភាពចម្រូងចម្រាស[7]។ ចៅក្រមរូបនេះបានស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺផ្សេងៗ និង ដាក់ដែនកំណត់ចំពោះការប្រើប្រាស់ JCE ទម្រង់ទី ៣ ចាប់តាំងពីការកកើតទ្រឹស្តីនេះ[8]។ នៅក្នុងការវិភាគយុត្តិសាស្ត្រ JCE ចាប់តាំងពីរឿងក្តី *Tadic* ចៅក្រមរូបនេះបានផ្តល់នូវយោបល់ណែនាំដូចខាងក្រោម៖

> ខ្ញុំសូមលើកឡើងថា សេរីភាពរបស់ចៅក្រមចំពោះសញ្ញាណមួយនេះ គួរតែធ្វើឱ្យចៅក្រមពិចារណាឱ្យបានប្រុងប្រយ័ត្ន និងមានសុភវិនិច្ឆ័យត្រឹមត្រូវ នៅពេលវាយតម្លៃលើភស្តុតាង និង បង្ហាញអំពីអត្ថិភាពនៃអំពើឧក្រិដ្ឋ និង ចេតនាឧក្រិដ្ឋ។ ក្នុងករណីមានវិមតិសង្ស័យ ចៅក្រមគួរតែជ្រើសរើសសម្រេចថាមិនមានពិរុទ្ធភាព។ ម្យ៉ាងវិញទៀត ប្រសិនបើអយ្យការមានបំណងចោទប្រកាន់ជនទាំងឡាយឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្រោម JCE ទម្រង់ទី ៣ នោះ អយ្យការគួរគិតទឹក ក្នុងករណីសមស្រប អំពីលទ្ធភាពចោទប្រកាន់"ចុងចោទកម្រិតទី២" ពីឧក្រិដ្ឋកម្មស្រាលៗជាងឧក្រិដ្ឋកម្មទាំងឡាយដែលចោទប្រកាន់លើ "ចុងចោទកម្រិតទីមួយ"[9]។

4. លើសពីនេះទៀតសោត Cassese បានលើកឡើងថា តុលាការព្រហ្មទណ្ឌអន្តរជាតិប្រហែលត្រូវបានរារាំងក្នុងការអនុវត្ត JCE ទម្រង់ទី ៣ ដែលជាទម្រង់លាតសន្ធឹង[10]។ ក្រុមមេធាវីការពារក្តីសូមលើកឡើងថា ការអនុវត្តសហឧក្រិដ្ឋកម្មរួមដែលជាទ្រឹស្តី គួរតែយកមកធ្វើចំណាត់ការដោយប្រុងប្រយ័ត្ន ជាពិសេសនៅក្នុងបរិបទនៃ អ.វ.ត.ក ហើយជាពិសេសនោះ គឺទម្រង់ទី៣ ដែលជាទម្រង់លាតសន្ធឹងនេះតែម្តង។ ខណៈដែលមូលដ្ឋានផ្លូវច្បាប់ចំពោះទម្រង់នៃការទទួលខុសត្រូវនេះមាន

---

[7] ឯកសាររបស់ A. Cassese ស្តីពី "ដែនកំណត់សមស្របនៃការទទួលខុសត្រូវបុគ្គលក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម" ចេញផ្សាយក្នុងព្រឹត្តិបត្តិ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៥ ឆ្នាំ២០០៧ ទំព័រ ១០៩-១៣៣ ត្រង់ទំព័រ ១១០

[8] ឯកសាររបស់ A. Cassese ស្តីពី "ដែនកំណត់សមស្របនៃការទទួលខុសត្រូវបុគ្គលក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម" ចេញផ្សាយក្នុងព្រឹត្តិបត្តិ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៥ ឆ្នាំ២០០៧ ទំព័រ ១០៩-១៣៣។

[9] ឯកសាររបស់ A. Cassese ស្តីពី "ដែនកំណត់សមស្របនៃការទទួលខុសត្រូវបុគ្គលក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម" ចេញផ្សាយក្នុងព្រឹត្តិបត្តិ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៥ ឆ្នាំ២០០៧ ទំព័រ ១០៩-១៣៣ ត្រង់ទំព័រ ១៣៣

[10] ឯកសាររបស់ A. Cassese ស្តីពី "ដែនកំណត់សមស្របនៃការទទួលខុសត្រូវបុគ្គលក្រោមគោលការណ៍សហកម្មឧក្រិដ្ឋកម្មរួម" ចេញផ្សាយក្នុងព្រឹត្តិបត្តិ យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ លេខ៥ ឆ្នាំ២០០៧ ទំព័រ ១០៩-១៣៣ ត្រង់ទំព័រ ១៣២

ភាពមិនរឹងមាំ ទម្រង់នៃការទទួលខុសត្រូវនេះមិនត្រឹមតែយកមកអនុវត្តលើមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ[11] វាថែមទាំងយកមកអនុវត្តក្នុងលក្ខណៈទូលាយជាងនេះគឺលើក្រុមបុគ្គលទាំងឡាយផ្សេងទៀតផងដែរ។ ដូច្នេះ ករណីនេះអនុញ្ញាតិឱ្យធ្វើការជ្រើសរើសជនដែលត្រូវយកមកចោទប្រកាន់ក្រោមទម្រង់នៃការទទួលខុសត្រូវមួយនេះ តាមរូបភាពនយោបាយ។ ទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួមគួរតែធ្វើចំណាត់ការដោយប្រុងប្រយ័ត្ន ជាពិសេសទម្រង់លាតសន្ធឹង។ តាមរយៈការពិនិត្យពិច័យរបស់អ្នកសិក្សាស្រាវជ្រាវ ភាពអាចអនុវត្តទៅបាននៃទ្រឹស្តីនេះបានប្រែក្លាយឱ្យមានភាពចម្រូងចម្រាសនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា។

5. នៅក្នុងបណ្តឹងឧទ្ធរណ៍មួយនេះ ក្រុមមេធាវីការពារក្តីនឹងផ្តោតចំបងលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងពាក្យសុំរបស់ **អៀង ធីរិទ្ធ** ស្តីពីសហឧក្រិដកម្មរួម[12]។ ទោះបីជាយ៉ាងនេះក្តី ដោយសារពាក្យសុំនេះបានគាំទ្រលើពាក្យសុំរបស់ **អៀង សារី** ស្តីពីសហាកម្មឧក្រិដ្ឋកម្មរួមផងដែរនោះ ក្រុមមេធាវីការពារក្តីក៏ចង្អុលយោងលើឯកសារទាំងឡាយដែលក្រុមមេធាវីការពារក្តីរបស់ **អៀង សារី** បានដាក់ជូនផងដែរ។

## II. **បទដ្ឋានជាធរមានចំពោះបណ្តឹងឧទ្ធរណ៍**

6. នៅក្នុង"សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម"ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ អបជ បានកំណត់លក្ខណៈវិនិច្ឆ័យទាំងឡាយសម្រាប់ការច្រានចោលសេចក្តីសម្រេចរបស់ កសចស ដែលបានធ្វើឡើងតាមឆន្ទានុសិទ្ធិ ដោយ អបជ ចង្អុលយោងលើសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY

---

[11] មាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បញ្ជាក់ថាគោលបំណងនៃកិច្ចដំណើរការនីតិវិធីរបស់អ.វ.ត.ក. គឺដើម្បីកាត់សេចក្តី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មនិងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់និងទំនៀមទំលាប់អន្តរជាតិស្តីពីមនុស្សជាតិនិងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា"។

[12] សេចក្តីសន្និដ្ឋានរបស់ អៀង សារី ទាក់ទងការអនុវត្តទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌ ដែលហៅថា សហាកម្មឧក្រិដ្ឋកម្មរួម នៅចំពោះមុខអ.វ.ត.ក. យោងតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ សេចក្តីសន្និដ្ឋាននេះចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ដែលមានឯកសារលេខ D97/3/2 ត្រង់កថាខណ្ឌទី១៣។

នៅក្នុងរឿងក្ដីប្រឆាំងនឹង Slobodan Milosevic[13]។ ដូច្នេះ អបជ បានរកឃើញនូវ មូលហេតុ ពួនបី លអាចច្រានចោលសេចក្ដីសម្រេចរបស់ចៅក្រមសាលាដំបូងដែលបានធ្វើឡើងតាមឆន្ទានុសិទ្ធិ ពោលគឺ ប្រសិនបើសេចក្ដីសម្រេចដែលបានជំទាស់នោះ៖

(i) ផ្អែកលើការបកស្រាយមិនត្រឹមត្រូវនៃច្បាប់ជាធរមាន

(ii) ផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវទាល់តែសោះទៅលើអង្គហេតុ ឬ

(iii) អយុត្តិធម៌ ឬ មិនសមហេតុផល ដែលនាំឱ្យមានការរំលោភបំពានឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[14]។

7. ក្រុមមេធាវីការពារក្ដីសូមលើកឡើងថា ការរំលោភលើដីកាសម្រេចដែលមានការជំទាស់នេះគឺផ្អែកជាចំបងលើធាតុផ្សំមួយក្នុងចំណោមធាតុផ្សំចំនួនបី ពោលគឺលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន។ ក្រុមមេធាវីការពារក្ដីដាក់បណ្ដឹងឧទ្ធរណ៍គឺដោយសារតែមូលហេតុនេះហើយ។

8. វិធាន ៧៤(៣)(ក)នៃវិធានផ្ទៃក្នុងផ្ដល់នូវមូលដ្ឋានផ្លូវច្បាប់ចំពោះការប្ដឹងឧទ្ធរណ៍នេះ។ បទប្បញ្ញត្តិនេះ ចែងអំពីមូលដ្ឋាននៃការប្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក។

## III. មូលហេតុទី ១ នៃ បណ្ដឹងឧទ្ធរណ៍ - ការសម្អាងមិនគ្រប់គ្រាន់នៃភាពអាចអនុវត្តបាននៃ JCE ទម្រង់ទី៣

### ៣.១ សេចក្ដីផ្ដើម

9. មូលហេតុទី ១ នៃការប្ដឹងឧទ្ធរណ៍ជាប់ពាក់ព័ន្ធនឹងភាសាដែល កសចស បានប្រើប្រាស់នៅក្នុងការពន្យល់សេចក្ដីសន្និដ្ឋានរបស់ខ្លួន។ ខណៈសេចក្ដីសម្រេចរបស់ កសចស ដែលជាប់ទាក់ទង JCE ទម្រង់ទី ១ និង ទម្រង់ទី ៣ហាក់ដូចជាបញ្ជាក់ច្បាស់ សម្អាង JCE ទម្រង់ទី ៣ មានភាពមិនច្បាស់លាស់ និង ស្រពិចស្រពិល។ ហេតុដូច្នេះ វាទាមទារឱ្យច្រានចោលនូវដីកាសម្រេចនេះ។

---

[13] អង្គបុរេជំនុំជម្រះ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចលើសំណើសុំឱ្យស្វែងរកភស្ដុតាងដោះបន្ទុកនៅក្នុង Shared Materials Drive ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារលេខ D164/4/13 (សេចក្ដីសម្រេចអំពី SMD) ត្រង់កថាខណ្ឌទី២៦។

[14] សូមមើល រឿងក្ដីតទល់រវាង រដ្ឋអាជ្ញា និង *Slobodan Milosevic* ដែលត្រូវបានដកស្រង់នៅក្នុងកថាខណ្ឌទី២៦ នៃ សេចក្ដីសម្រេចស្ដីពី SMD។

00432542



## ៣.២ មូលដ្ឋានផ្លូវច្បាប់ដែលពាក់ព័ន្ធ

10. សេចក្ដីសម្រេចនីមួយៗរបស់តុលាការត្រូវផ្ដល់សម្អាងហេតុនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន។ ចំណុចនេះជាគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយតុលាការអ៊ឺរ៉ុប ដូចបានសម្រេចនៅក្នុងរឿងក្ដី *Hadjianastassiou ទល់នឹង Greece*០:

> តុលាការជាតិត្រូវតែ(...)ចង្អុលបញ្ជាក់ដោយមានការបំភ្លឺឱ្យបានគ្រប់គ្រាន់អំពីមូលដ្ឋានទាំងឡាយដែលខ្លួនយកមកសម្អាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន។ មានតែកត្តានេះទេ នៅក្នុងចំណោមកត្តាដទៃទៀត ដែលអាចឱ្យជនជាប់ចោទមានលទ្ធភាពអនុវត្តសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍របស់ខ្លួនយ៉ាងមានប្រសិទ្ធិភាព[15]។

11. កសចស ខកខានមិនបានអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ច្បាប់មួយនេះ ដែលបង្កើតជាមូលដ្ឋានផ្លូវច្បាប់សម្រាប់ការប្ដឹងឧទ្ធរណ៍។

## ៣.៣ សំណើ

12. កសចស បានសរសេរសេចក្ដីសន្និដ្ឋានរបស់ខ្លួនអំពីភាពអាចអនុវត្តទៅបាននៃ JCE ទម្រង់ទី ៣ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងឡាយដូចខាងក្រោម៖

> សម្រេចទទួលយកដោយផ្នែកនូវសំណើសុំដែលផ្ញើមកនេះ ដោយហេតុថាធាតុផ្សំអត្តនោម័តនៃ JCEIII ដែលអាចត្រូវអនុវត្តបាននៅមុខ អ.វ.ត.ក គឺមានតែការទទួលយកជាអត្តនោម័តនៃផលវិបាកជាលក្ខណៈធម្មជាតិ និង អាចព្យាករបាននៃការអនុវត្តផែនការរួមតែប៉ុណ្ណោះ[16]។

13. ក្រុមមេធាវីការពារក្ដីសូមលើកឡើងថា វាមិនមានភាពច្បាស់លាស់ថាតើ កសចស សំដៅលើសំណើអ្វី។ ខណៈដែលទំព័រទី២នៃដីកាសម្រេច បានកំណត់សេចក្ដីសន្និដ្ឋានដំបូងរបស់ **អៀង សារី** ស្ដីពី JCE ថាជា “សំណើ” (សំណើរបស់ **អៀង សារី** ស្ដីពីសហឧក្រិដ្ឋកម្មរួម)[17] ដីកាសម្រេចនេះ

---

[15] រឿងក្ដី *Hadjianastassiou* និង *Greece* សាលក្រម ចេញដោយតុលាការអ៊ឺរ៉ុប ឯកសារលេខ 12945/87 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ ត្រង់កថាខណ្ឌទី៣៣។

[16] ដីកាដែលត្រូវបានជំទាស់ ត្រង់កថាខណ្ឌទី១០

[17] ញត្តិរបស់ អៀង សារី ប្រឆាំងការអនុវត្តនៅចំពោះមុខអ.វ.ត.ក. នូវទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌ ហៅថាសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ឯកសារលេខ D97 (ញត្តិទាក់ទង JCE របស់ អៀង សារី)។ ក្រោយមកទៀត

ក៏ចង្អុលយោងលើសំណើផ្សេងៗទៀត ដែលបានធ្វើឡើងដោយភាគីដទៃទៀតផងដែរ។ ដីកាសម្រេចនេះហាក់ដូចជានិយាយក្តោបរួមលើពាក្យសុំរបស់ **អៀង ធីរិទ្ធ** ស្តីពី JCE ផង ដែរ[18]។ តាមការពិត សំណើមួយចំនួនបានរៀបចំឡើងដោយក្រុមមេធាវីការពារក្តីផ្សេងៗគ្នា ជាពិសេសទាក់ទងនឹង JCE ទម្រង់ទី ៣។ វាមិនមានភាពច្បាស់លាស់ថាតើ កសចស សំដៅ លើ ចំនុចមួយណាជាក់លាក់នៅក្នុងសំណើទាំងឡាយរបស់ក្រុមមេធាវីការពារក្តីនោះ នៅក្នុងសម្រង់សំដីខាងលើនេះ។ ហេតុដូច្នេះ វាមិនអាចបញ្ជាក់ថាតើដីកាសម្រេចនោះទទួលយកផ្នែកមួយណានៅក្នុងសំណើ។

14. ម្យ៉ាងវិញទៀត ឃ្លាដែលបានប្រើប្រាស់នៅក្នុងសំដីខាងលើដែលដកស្រង់ចេញពីដីកានោះ មិនមានលក្ខណៈច្បាស់លាស់ ដោយបានលើកឡើងថា ទទួលយកសំណើនេះដោយផ្អែកត្រង់ចំនុចទាក់ទងនឹង JCE ទម្រង់ទី ៣ ជាពិសេស សម្រង់សំដីនោះបានលើកឡើងអំពី“ការទទួលយកដោយអត្តនោម័ត”ចំពោះផលវិបាកផ្សេងៗ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់សាលាក្តី ICTY នៅក្នុងរឿងក្តី *Kvocka* បានពិចារណាដូចខាងក្រោម៖

> ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍កត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានដាក់ឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងនៅក្រៅរង្វង់នៃគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ ទោះបីជាដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍សូមបញ្ជាក់ថា ជនជាប់ចោទអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តឡើងនៅក្រៅរង្វង់នៃគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ជាលក្ខណៈប្រព័ន្ធ ប្រសិនបើឧក្រិដ្ឋកម្មទាំងនោះជាផលវិបាកកើតឡើងដោយឯកឯង និង អាចព្យាករបាន។ ប៉ុន្តែយើងត្រូវបញ្ជាក់ថា ករណីនេះត្រូវតែធ្វើការវាយតម្លៃលើការដឹងរបស់ជនជាប់ចោទម្នាក់ៗ។ ករណីនេះមានសារៈសំខាន់ចំពោះ JCE ទម្រង់ជាលក្ខណៈប្រព័ន្ធ ដែលទម្រង់នេះអាចជាប់ពាក់ព័ន្ធនឹងអ្នកចូលរួមច្រើននាក់តាមរយៈតួនាទីខុសៗគ្នា និង តួនាទីនៅដាច់ដោយឡែកពីឧក្រិដ្ឋកម្ម។ លក្ខណៈឯកឯង និង អាចព្យាករបានចំពោះបុគ្គលម្នាក់មួយរូប ដែលបានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ទម្រង់ជាលក្ខណៈ

---

អៀង សារី បានដាក់ឯកសារបន្ថែម គឺសេចក្តីសង្កេតបន្ថែមរបស់ អៀង សារី ទាក់ទងការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅអ.វ.ត.ក. ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ D97/7 (ញត្តិបន្ថែមរបស់ អៀង សារី ញត្តិទាំងអស់នេះហៅថា ញត្តិស្តីពី JCE របស់ អៀង សារី)។

[18] ដីកាដែលត្រូវបានជំទាស់ ត្រង់កថាខណ្ឌទី២-៣ ។

ប្រព័ន្ធនោះ អាចមិនមែនជាលក្ខណៈឯកឯង និង មិនអាចព្យាករបានចំពោះបុគ្គលម្នាក់ទៀត ដោយវាអាស្រ័យលើព័ត៌មានដែលជនទាំងនេះទទួលបានតែប៉ុណ្ណោះ។ ដូច្នេះ ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ទម្រង់ជាលក្ខណៈប្រព័ន្ធ មិននាំឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្ម*ទាំងអស់*នោះទេ។ ទោះបីឧក្រិដ្ឋកម្មទាំងអស់នេះមិនស្ថិតនៅក្នុងគោលបំណងរួមនៃសហគ្រាសនេះក៏ដោយ ឧក្រិដ្ឋកម្មទាំងអស់នេះជាផលវិបាកដោយឯកឯង ឬ ជាផលវិបាកដែលអាចព្យាករបានដែលកើតចេញពីសហគ្រាសនេះ។ អ្នកចូលរួមណាក៏ដោយអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មបែបនេះបាន ក្នុងករណីដែលអយ្យការបង្ហាញឱ្យឃើញថា ជនជាប់ចោទបានដឹងគ្រប់គ្រាន់ថា ឧក្រិដ្ឋកម្មទាំងនេះគឺជាផលវិបាកដោយឯកឯង និង ដែលខ្លួនអាចព្យាករបាន[19]។

15. សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *Kvocka* បានពន្យល់ថា JCE ទម្រង់ទី ៣ អនុវត្តតែករណីដែលគេអាចបង្ហាញឱ្យឃើញថា ជនជាប់ចោទបានដឹងដោយពិតប្រាកដ ហើយ ផលវិបាកដោយឯកឯង និង ដែលអាចព្យាករបាននោះ វាអាស្រ័យលើការយល់ឃើញជាក់លាក់តាមរយៈការដឹងរបស់ជនជាប់ចោទ ដែលករណីនេះវាខុសគ្នាពីបុគ្គលមួយទៅបុគ្គលមួយ។ ដូច្នេះ ការបកស្រាយលើការដឹងនេះគឺជាកិច្ចមួយធ្វើឡើងដោយអត្តនោម័ត។ JCE ទម្រង់ ទី ៣ មិនត្រឹមតែទាមទារឱ្យបង្ហាញអំពីការដឹងប៉ុណ្ណោះទេ វាថែមទាំងឱ្យបុគ្គលម្នាក់បកស្រាយការដឹងនោះដោយធ្វើយ៉ាងណាបង្ហាញថា ឧក្រិដ្ឋកម្មនេះជាផលវិបាកដោយឯកឯង និង ដែលបុគ្គលម្នាក់អាចព្យាករបានថា ឧក្រិដ្ឋកម្មទាំងនេះនឹងកើតឡើងក្រៅវិសាលភាពនៃសហគ្រាសរបស់ខ្លួន។

16. ការពន្យល់ខាងលើដោយសម្អាងលើអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *Kvocka* មិនបានឆ្លុះបញ្ចាំងនៅក្នុងដែលការសម្រេចដែលត្រូវបានជំទាស់នេះទេ។ ភាសាដែល កសចស បានប្រើប្រាស់ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន មិនមានលក្ខណៈច្បាស់លាស់ និងមានលក្ខណៈស្រពិច

---

[19] រឿងក្តី រដ្ឋអាជ្ញា និង *Kvocka និងអ្នកដទៃទៀត* តុលាការឧទ្ធរណ៍ សាលដីកា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ សំណុំរឿងលេខ IT-98-30/1-A ត្រង់ទំព័រ៨៦។ កថាខណ្ឌនេះត្រូវបានយោងនៅក្នុងដីកាដែលត្រូវបានជំទាស់ ត្រង់ជើងទំព័រ ៣៤ និង ៤០ ប៉ុន្តែផ្នែកពាក់ព័ន្ធនៃសេចក្តីដកស្រង់ខាងលើនេះ ដែលមានសារៈសំខាន់ក្នុងការពន្យល់វាក្យស័ព្ទប្រើប្រាស់ដោយក.ស.ច.ស. ("ការទទួលយកតាមគោលការណ៍អត្តនោម័ត") មិនត្រូវបានយោងនោះទេ។ សេចក្តីពន្យល់នៅក្នុងរឿងក្តី Kvocka ស្តីពីសហកម្មឧក្រិដ្ឋកម្មរួមទម្រង់លេខ III (JCE III) ផ្តល់ឱ្យជាវិសាលភាពតូចចង្អៀតជាងអ្វីដែលផ្តល់ឱ្យដោយសាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ *Tadic* សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់ជាមួយ *Dusko Tadic* សាលក្រមរបស់តុលាការឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ សំណុំរឿងលេខ IT-94-1-A ត្រង់កថាខណ្ឌ ២៨៨។

ស្រពិល។ ដូច្នេះ ដីកាសម្រេចនេះទុកឱ្យភាគីទាំងឡាយ និងអាជ្ញាធរស៊ើបអង្កេតខ្លួនឯងបកស្រាយទាំងស្រពិចស្រពិលលើទ្រឹស្តីនេះ។

17. ជាពិសេស ដោយពិចារណាលើភាពចម្រូងចម្រាស និង ការរិះគន់ជុំវិញ JCE នេះ ការបកស្រាយជាក់លាក់លើទ្រឹស្តីនេះដើម្បីអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដាច់ខាតត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន និង ច្បាស់លាស់[20]។ ប៉ុន្តែ ដីកាសម្រេចដែលមានការជំទាស់បានបន្សល់ទុកនូវនិយមន័យមួយដែលមិនសមស្របសម្រាប់ភាគីទាំងឡាយ។ ការធ្វើដូច្នេះដូចជាយើងមិនខ្វល់ពីភាពស្មុគស្មាញនៃទ្រឹស្តីនេះឡើយ ដែលត្រូវបានអង្គជំនុំជម្រះនានា និង សាលាក្តីផ្សេងៗទៀតកំណត់ន័យ និង ធ្វើការបកស្រាយផ្សេងៗគ្នា នៅពេលយកមកអនុវត្ត។

18. បន្ថែមលើចំនុចនេះ ដីកាសម្រេចមានលក្ខណៈពុំច្បាស់លាស់ថាតើប្រយោគ“ការទទួលយកដោយអត្តនោម័តនៃផលវិបាកដោយឯកឯង និង ដែលអាចព្យាករបានចំពោះការអនុវត្តផែនការរួមនេះ” ដែលបានដកស្រង់ចេញពីកថាខណ្ឌទី ១២ ខាងលើនេះ មានន័យដូចម្តេចដែរ[21]។ នៅពេលដែលមិនមានការបែងចែកដែនកំណត់ឱ្យបានច្បាស់លាស់ចំពោះទម្រង់សហឧក្រិដ្ឋកម្មរួមនីមួយៗនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ វាបានរារាំងក្រុមមេធាវីការពារក្តីពីការត្រៀមរៀបចំការការពាររបស់ខ្លួនឱ្យបានសមស្រប ហើយវាមិនបានផ្តល់បទដ្ឋានណែនាំសមរម្យសម្រាប់អាជ្ញាធរស៊ើបអង្កេត។

19. បន្ថែមលើភាពស្រពិចស្រពិលដែលបានលើកឡើងខាងលើនេះ ដីកាសម្រេចបានលើកឡើងថាសំណើររបស់មេធាវីការពារក្តីត្រូវបានទទួលយកដោយផ្នែក[22]។ ភាសានេះលើកឡើងថា

---

[20] Elies van Sliedrecht លើកឡើងថា៖ “តុលាការឧទ្ធរណ៍លើរឿងក្តី Tadic មិនបានដោះស្រាយបញ្ហា JCE ឲ្យបានច្បាស់លាស់នោះទេ។ ទីមួយ តុលាការនេះប្រើទស្សនទាននៃ JCE នៅក្នុងនៃ “ប្រព្រឹត្ត” ហើយបែងចែកន័យនេះចេញពីការជួយនិងជម្រុញឧក្រិដ្ឋកម្មណាមួយ ដែលការជួយនិងជម្រុញឧក្រិដ្ឋកម្មហ្នឹង ត្រូវបានតុលាការនេះប្រើក្នុងន័យថា “ចូលរួម” នៅក្នុងបទល្មើស២៧ណាមួយ ហើយការឲ្យនិយមន័យនេះត្រូវបានគេយល់ថា “បន្ទាបកម្រិតទទួលខុសត្រូវព្រហ្មទណ្ឌ”។ ទីពីរនោះគឺ តុលាការឧទ្ធរណ៍នេះកំណត់ទៅលើគោលបំណងសាមញ្ញ ឬ JCE ថាជា “ទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងបទផ្សំគំនិត”។ ធ្វើឲ្យបញ្ហានេះកាន់តែស្មុគស្មាញថែមទៀត តុលាការសាលាឧទ្ធរណ៍នេះបានប្រើប្រាស់ពាក្យ “ចារី” និង “សហចារី” ដើម្បីសំដៅទៅលើជនណាម្នាក់ចូលរួមក្នុង JCE។ សូមមើលឯកសាររបស់ E. van Sliedrecht ស្តីពី “សហកម្មឧក្រិដ្ឋកម្មរួមជាមធ្យោបាយដើម្បីដាក់ទោសបុគ្គលសម្រាប់អំពើប្រល័យពូជសាស្ត្រ” ចេញផ្សាយក្នុងព្រឹត្តិបត្តិច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ៥ ឆ្នាំ២០០៧ ទំព័រ ១៨៧-២០៧ ត្រង់ទំព័រ ១៨៩-១៩០។

[21] ដីកាដែលត្រូវបានជំទាស់ ត្រង់កថាខណ្ឌទី១០

[22] ដីកាដែលត្រូវបានជំទាស់ ត្រង់កថាខណ្ឌទី១០

00432546



ទឡ្ហីករណ៍របស់មេធាវីការពារក្ដីដែលជំទាស់លើ JCE ទម្រង់ទី ៣ ត្រូវបានទទួលយកដោយផ្នែក។ យើងមិនដឹងច្បាស់ថាតើ កសចស ទទួលយកផ្នែកណាមួយនៃការជំទាស់របស់មេធាវីការពារក្ដីដែលបានលើកឡើងយ៉ាងក្បោះក្បាយអំពី JCE ទម្រង់ទី ៣ នោះទេ។ ទោះបីជាយ៉ាងនេះក្ដី ដោយពិចារណាលើការទទួលយកដោយផ្នែក កសចស បានទទួលស្គាល់ថា និយមន័យជាក់លាក់នៃ JCE ទម្រង់ទី ៣ ដែលខ្លួនបានប្រើប្រាស់នោះ មានលក្ខណៈមិនសូវទូលំទូលាយដូចទស្សនទានដែលបានទទួលស្គាល់ជាទូទៅ និង ដែលបានប្រើប្រាស់ដោយសាលាក្ដី ICTY។ តើអ្វីទៅជាភាពខុសគ្នាពិតប្រាកដរវាងការបង្កើតទស្សនទាននេះឡើងដោយ កសចស និង សាលាក្ដី ICTY នៅមានភាពមិនច្បាស់លាស់ ដែលត្រូវយកមកដោះស្រាយនៅក្នុងដំណាក់កាលបណ្ដឹងឧទ្ធរណ៍នេះ។

## ៣.៤ សេចក្ដីសន្និដ្ឋាន

20. ករណីនេះបណ្ដាលឱ្យមានការបកស្រាយមួយមិនត្រឹមត្រូវលើច្បាប់ជាធរមាន ឬ យ៉ាងហោចណាស់វាជាការបកស្រាយមួយដែលមិនបានផ្ដល់សម្អាងហេតុគ្រប់គ្រាន់ ហើយមិនអាចធ្វើឱ្យយើងយល់បាន។ ដូច្នេះ កសចស ខកខានមិនបានបញ្ជាក់បំភ្លឺឱ្យបានគ្រប់គ្រាន់លើមូលដ្ឋានដែលខ្លួនយកមកសម្អាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ដូចដែលបានទាមទារនៅក្នុងរឿងក្ដី *Hadjianastassiou ទល់នឹង Greece*។ ការខកខានមិនបានធ្វើដូច្នេះបណ្ដាលឱ្យវាក្លាយទៅជាមូលដ្ឋានសម្រាប់ការប្ដឹងឧទ្ធរណ៍ ហើយដីកាសម្រេចនេះ ត្រូវតែច្រានចោលទុកជាឥតបានការដោយសារមូលដ្ឋាននេះ។

## IV. មូលហេតុទី ២ នៃ បណ្ដឹងឧទ្ធរណ៍ - ការខកខានមិនបានផ្ដល់សម្អាងហេតុក្នុងការច្រានចោលទឡ្ហីករណ៍ទាំងឡាយរបស់មេធាវីការពារក្ដីប្រឆាំងនឹង *Tadic*

## ៤.១ សេចក្ដីផ្ដើម

21. សំណើរបស់ **អៀង សារី** អំពីសហឧក្រិដ្ឋកម្មរួម បានផ្ដល់ទឡ្ហីករណ៍ថា ការពិចារណារបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្ដី *Tadic* ចំពោះការបង្កើត JCE នៅក្នុងរឿងក្ដីនោះគួរតែកុំឱ្យយកមកអនុវត្តឱ្យដូចគ្នានៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[23]។ សំណើទាំងនេះបានគាំ

---

[23] សូមមើលញត្តិរបស់ អៀង សារី ស្ដីពី JCE ត្រង់កថាខណ្ឌ ១ និង ៥ ក្នុងចំណោមកថាខណ្ឌដទៃទៀត។

ទូបន្ថែមដោយក្រុមមេធាវីការពារក្ដីរបស់ **អៀង ធីរិទ្ធ** នៅក្នុងសំណើអំពីសហឧក្រិដ្ឋកម្មរួម[24]។ កសចស ខកខានមិនបានផ្ដល់សម្អាងហេតុចំពោះការបដិសេធដោយមិនច្បាស់លាស់លើទឡ្ហីករណ៍នេះ។

## ៤.២ មូលដ្ឋានច្បាប់ពាក់ព័ន្ធ

22. សេចក្ដីសម្រេចរបស់តុលាការនីមួយៗត្រូវផ្ដល់នូវសម្អាងហេតុនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន។ ដូចបានលើកឡើងនៅក្នុងផ្នែកទី ៣.២ ខាងលើ ចំនុចនេះអាចចាត់ទុកថាជាគោលការណ៍ទូទៅនៃច្បាប់ ហើយត្រូវបានទទួលស្គាល់ដោយតុលាការអឺរ៉ុបនៅក្នុងរឿងក្ដី *Hadjianasassiou ទល់នឹង Greece*[25]។

23. កសចស មិនបានគោរពតាមគោលការណ៍ច្បាប់នេះ ដែលជាហេតុបង្កើតជាមូលដ្ឋានផ្លូវច្បាប់សម្រាប់ការប្ដឹងឧទ្ធរណ៍។

## ៤.៣ សំណើ

24. ខណៈដែលសំណើរបស់ **អៀង សារី** និង **អៀង ធីរិទ្ធ** ស្ដីពីសហឧក្រិដ្ឋកម្មរួម បានអះអាងថា រឿងក្ដី*Tadic* បានបង្កើតជាយុត្តិសាស្ត្រមួយដែលមិនពេញលេញនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ផ្អែកតាមសារណារបស់ Kai Ambos អ្នកដែលមិនមែនភាគីនៅក្នុងរឿងក្ដី កសចស មិនបានតវ៉ាជំទាស់នឹងទឡ្ហីករណ៍នេះ[26]។ កសចស បែរជាផ្អែកលើតែសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្ដី *Tadic* និង *Kvocka* ស្ទើរតែទាំងស្រុង ដោយមិនបានធ្វើការពន្យល់បន្ថែម ហើយបានសន្និដ្ឋានដោយផ្អែកលើមូលដ្ឋានថា៖

> ដោយបានពិចារណាឃើញថា យុត្តិសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃ

---

[24] សេចក្ដីសន្និដ្ឋានរបស់ អៀង សារី ទាក់ទងការអនុវត្តទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌ ដែលហៅថា សហកម្មឧក្រិដ្ឋកម្មរួម នៅអ.វ.ត.ក. យោងតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ សេចក្ដីសន្និដ្ឋាននេះចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារលេខ D97/3/2 កថាខណ្ឌទី១៣។

[25] រឿងក្ដី *Hadjianastassiou តទល់នឹង Greece* សាលក្រមរបស់តុលាការអឺរ៉ុប ឯកសារលេខ 12945/87 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ ត្រង់កថាខណ្ឌទី៣៣។

[26] សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីពាក់ព័ន្ធសំណុំរឿងលេខ 001/18-07-2007-ECCC/OCIJ(PTC02) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារលេខ D99/3/27 (សំណុំរឿងលេខ 001) (សារណារបស់ Kai Ambos)។

អំពី JCE ត្រូវបានតាក់តែងឡើងមុនពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរនៅមុខ អ.វ.ត.ក កើតឡើង សហចៅក្រមស៊ើបអង្កេតយល់ឃើញថា JCE អាចអនុវត្តទៅបានដោយផ្អែកលើមូលដ្ឋានដែលមានកំណត់នៅក្នុងច្បាប់អន្តរជាតិ ដូចដែលមានលើកឡើងនៅក្នុងកថាខណ្ឌ ១៥-១៧ រួមទាំង កំណត់យោងចុងទំព័រដែលទាក់ទងនឹងការវាយតម្លៃជាអត្តនោម័តនៃផលវិបាកជាលក្ខណៈធម្មជាតិ និង អាចព្យាករជាមុន[27]។

25. ដែលការសម្រេចដែលត្រូវបានជំទាស់នេះមិនបានពន្យល់អំពីហេតុផលអ្វី ដែលដីកានេះគេចចេញមិនឆ្លើយតបនឹងទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីទាក់ទងនឹងចំនុចនេះ ហើយដីកាសម្រេចនេះសម្រេចផ្អែកលើយុត្តិសាស្ត្រមួយដែលត្រូវបានគេជំទាស់តវ៉ា ដោយមិនបានលើកឡើង ឬ ឆ្លើយតបនឹងការតវ៉ាជាក់លាក់នោះ។ ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិផ្អែកលើយុត្តិសាស្ត្រមួយចំនួន និងច្រាន ចោលយុត្តិសាស្ត្រដទៃទៀត។ បើទោះជាយ៉ាងនេះមែន រឿងក្តីជាក់លាក់ទាំងនេះ ត្រូវបានក្រុមមេធាវីការពារក្តីជំទាស់ ដោយបានលើកនូវទឡ្ហីករណ៍យ៉ាងពិស្តារ និងដោយមានហេតុផល។ នៅក្នុងករណីនេះ ចៅក្រមមានកាតព្វកិច្ចបញ្ជាក់បំភ្លឺអំពីមូលហេតុដែលខ្លួនបដិសេធទឡ្ហីករណ៍ជាក់លាក់របស់ក្រុមមេធាវីការពារក្តី។ តាមការពិត ទឡ្ហីករណ៍របស់មេធាវីការពារក្តី ស្របនឹងគោលការណ៍ច្បាប់ ដែលតម្រូវឱ្យអជ្ញាធរតុលាការផ្តល់សម្អាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដូចដែលបានពន្យល់តាមរយៈយុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស ដែលបានលើកឡើងខាងលើ[28]។

## ៤.៤ សេចក្តីសន្និដ្ឋាន

26. ក្រុមមេធាវីការពារក្តីសូមលើកឡើងថា ការខកខានមិនបានឆ្លើយតបនឹងទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តី ដែលជំទាស់នឹងយុត្តិសាស្ត្រនៅក្នុងរឿងក្តី *Tadic* និង យុត្តិសាស្ត្រដែលពាក់ព័ន្ធនៅក្នុងសាលាក្តី ICTY វាបានផ្តល់ជាមូលដ្ឋានសម្រាប់ការប្តឹងឧទ្ធរណ៍នេះ។ ឈរលើមូលដ្ឋាននេះដែលការសម្រេចដែលត្រូវបានជំទាស់នេះត្រូវតែច្រានចោលចាត់ទុកថាឥតបានការ។

---

[27] ដីកាដែលត្រូវបានជំទាស់ ត្រង់កថាខណ្ឌទី២១

[28] រឿងក្តី *Hadjianastassiou តទល់នឹង Greece* សាលក្រមរបស់តុលាការអ៊ឺរ៉ុប ឯកសារលេខ 12945/87 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ ត្រង់កថាខណ្ឌទី៣៣។

27. នៅក្នុងមូលដ្ឋានទី ៧ សម្រាប់ការប្តឹងឧទ្ធរណ៍ខាងក្រោម ក្រុមមេធាវីការពារក្តីនឹងពន្យល់រៀបរាប់លើខ្លឹមសារសំខាន់នៃទឡ្ហីករណ៍ស្តីពី JCE ហើយនឹងផ្តល់ទឡ្ហីករណ៍ដោយឡែកថាហេតុអ្វីបានជាយុត្តិសាស្ត្រនៅក្នុងរឿងក្តី *Tadic* និង យុត្តិសាស្ត្រដែលពាក់ព័ន្ធនៅក្នុងសាលាក្តី ICTY មិនអាចយកមកអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ចំនុចនេះបានបង្កើតជាមូលដ្ឋានដោយឡែកមួយទៀតសម្រាប់ការប្តឹងឧទ្ធរណ៍ ដែលវាពាក់ព័ន្ធនឹងអង្គច្បាប់។

## V. មូលហេតុទី៣ នៃបណ្តឹងឧទ្ធរណ៍- ការខកខានមិនបានលើកឡើងនូវទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលថា JCE ទម្រង់ទី ១ និង ទម្រង់ទី ៣ មិនបានសម្អាងឱ្យបានសមស្រប

### ៥.១ សេចក្តីផ្តើម

28. នៅក្នុងសំណើរបស់ **អៀង ធីរិទ្ធ** អំពីសហឧក្រិដ្ឋកម្មរួម ក្រុមមេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍យ៉ាងក្បោះក្បាយ និង ពិស្តារថា JCE មិនបានសម្អាងឱ្យបានសមស្របនៅក្នុងដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរ[29]។ កសចស មិនបានលើកឡើងទឡ្ហីករណ៍នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន និងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន។ ហេតុដូច្នេះ វាបណ្តាលឱ្យមានកំហុសអង្គច្បាប់។

### ៥.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ

29. បទដ្ឋានផ្លូវច្បាប់ចំពោះមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ គឺជាការច្របាច់បញ្ចូលគ្នារវាងសម្អាងហេតុដែលមិនពេញលេញ ដែលមូលដ្ឋាននេះបានលើកឡើងនៅក្នុងផ្នែកទី ៣.២ ខាងលើរួចហើយ និងការបកស្រាយច្បាប់ជាធរមានសម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.តក ដោយមិនត្រឹមត្រូវ ដែលចំនុចនេះជាមូលដ្ឋានទី ១ សម្រាប់ការបដិសេធចោលសេចក្តីសម្រេចរបស់កសចស ដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងកាលពីលើកមុន[30]។

30. កសចស មិនបានគោរពតាមគោលការណ៍ច្បាប់នេះ ដែលបង្កើតជាមូលដ្ឋានផ្លូវច្បាប់នៃការប្តឹងឧទ្ធរណ៍នេះ។

---

[29] ញត្តិរបស់ អៀង ធិរិទ្ធ ស្តីពី JCE ត្រង់ផ្នែក៣.៣ "JCE មិនត្រូវបានលើកឡើងសមស្របនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ" ត្រង់កថាខណ្ឌទី១៨-២៣។

[30] សេចក្តីសម្រេចទាក់ទង SMD ត្រង់កថាខណ្ឌទី២៦

## ៥.៣ សំណើ

31. យោងលើសាលដីការបស់អង្គបុរេជនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងរឿងក្តី **ឌុច**[31] ដែលនៅក្នុងសាលាដីកានេះ អង្គបុរេជំនុំជម្រះបានសម្រេចថា ការបង្កើតទម្រង់នៃការទទួលខុសត្រូវមួយនេះនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានលក្ខណៈស្រពិចស្រពិល ក្រុមមេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍នៅក្នុងសំណើដំបូងរបស់ខ្លួនថា JCE ដែលបានសម្អាងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងរឿងក្តីលេខ ០០២ មានលក្ខណៈស្រពិចស្រពិល និង មិនច្បាស់លាស់ដូចគ្នានឹងរឿងក្តី ០០១។ ក្រុមមេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍ថា៖

> ទម្រង់ផ្សេងៗគ្នានៃ JCE ដែលបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណី ឌុច មានលក្ខណៈពិសេស និង ច្បាស់លាស់ជាង JCE ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០២[32]។

32. អង្គបុរេជំនុំជម្រះបានសម្រេចបន្ថែមទៀតនៅក្នុងសាលដីកានោះថា៖

> ការបញ្ជាក់ឱ្យបានច្បាស់លាស់មានភាពចាំបាច់ ដើម្បីធ្វើការវែកញែកទស្សនៈទាននៃសហឧក្រិដ្ឋកម្មរួម ពីទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ដែលស្រដៀងគ្នា ហើយដែលអាចនៅជាធរមាន អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[33]។

33. នៅពេលនិយាយអំពីដំណាក់កាលនៃការចេញដីកាដំណោះស្រាយ វាក៏ត្រូវអនុវត្តដូចគ្នាចំពោះដំណាក់កាលស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតខ្លួនឯងបានសម្រេចយ៉ាងត្រឹមត្រូវនៅក្នុងកថាខណ្ឌទី ១០ នៃដែលការសម្រេចដែលត្រូវបានជំទាស់ថា៖

> សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែឆ្លើយតបទៅនឹងសំណើនេះដើម្បីផ្តល់នូវព័ត៌មានគ្រប់គ្រាន់ស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមិនមានចែងច្បាស់នៅក្នុង

---

[31] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ សំណុំរឿងលេខ ០០១ ឯកសារលេខ D99/3/42 (សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងដីកាដំណោះស្រាយ)។

[32] ញត្តិរបស់ អៀង ធិរិទ្ធ ស្តីពី JCE ត្រង់កថាខណ្ឌទី១៩

[33] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ១៣៥

ច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀង។

34. អង្គបុរេជំនុំជម្រះបានលើកឡើងបន្ថែមទៀតថា ដោយសារតែការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមត្រូវបានសម្អាងពីដំបូងយ៉ាងសមរម្យនៅក្នុងដីកាសន្និដ្ឋានស្ពាពរ បានន័យថា ក្រោយពីដំណាក់កាលស៊ើបអង្កេត "JCE មិនបានបង្កើតជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុសម្រាប់ការស៊ើបសួរ។ ដោយសារមូលហេតុនេះ អង្គបុរេជំនុំជម្រះនឹងមិនបន្ថែមបទចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យទៅជំនុំជម្រះនៅក្នុងដំណាក់កាលនេះឡើយ"[34]។ ករណីនេះអាចអនុវត្តដូចគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២។

35. ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីដូចបានគូសបញ្ជាក់នៅក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះពិចារណាឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់នូវមូលដ្ឋានអង្គហេតុចំពោះសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ១ និង ទម្រង់ទី ៣។ ខណៈដែលកថាខណ្ឌទី ៥-១៦ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររៀបរាប់តែអំពី JCE ទម្រង់ទី ២ សេចក្តីសន្និដ្ឋាននៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងកថាខណ្ឌទី ១១៦ ក៏បានផ្អែកលើ JCE ទម្រង់ទី ១ និង ទម្រង់ទី ៣ ដោយមិនបានយោងទៅវកភស្តុតាងជាក់លាក់ដែលនឹងផ្តល់ជាមូលដ្ឋានចំពោះ JCE ទម្រង់ទាំងពីរនេះឡើយ។ ដូច្នេះ ទម្រង់ទាំងពីរនេះមិនបានសម្អាងឱ្យបានសមស្របហើយមិនមានភាពច្បាស់លាស់ ដែលជាលក្ខខណ្ឌកំណត់ដោយអង្គបុរេជំនុំជម្រះ។ ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី ១៨-២៣នៅក្នុងសំណើរបស់ **អៀង ធីរិទ្ធ** ស្តីពីសហឧក្រិដ្ឋកម្មរួម ត្រូវបានយកមកដាក់យោងបញ្ចូលគ្នា។

## ៥.៤ សេចក្តីសន្និដ្ឋាន

36. ដែលការសម្រេចមិនបានផ្តល់សម្អាងហេតុឱ្យបានគ្រប់គ្រាន់នៅក្នុងផ្នែកនៃសេចក្តីសម្រេចរបស់ខ្លួនដែលនៅក្នុងនោះមិនបានឆ្លើយតបនឹងទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីដែលថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទី ១ និង ទម្រង់ទី ៣ មិនបានសម្អាងឱ្យបានសមស្របនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នេះជាលក្ខខណ្ឌមួយដែលអនុញ្ញាតិឱ្យជនត្រូវចោទទទួលបានការជូនដំណឹងគ្រប់គ្រាន់អំពីទម្រង់នៃការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីមួយនេះ។ ដូច្នេះ ដីកាសម្រេចនេះមិនបានផ្តល់សម្អាងហេតុឱ្យបានគ្រប់គ្រាន់ ហើយបានបង្កើតជាកំហុស

[34] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ១៤១

អង្គច្បាប់មួយ ដែលតម្រូវឱ្យប្រានដីកានេះចោលចាត់ទុកជាឥតបានការ។

37. ប៉ុន្តែ ក្រុមមេធាវីការពារក្តីសូមស្នើឱ្យអង្គបុរេជំនុំជម្រះសម្រេចផ្ទុយពីនេះវិញថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទី ១ និង ទម្រង់ទី ៣ មិនបានសម្អាងឱ្យបានគ្រប់គ្រាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហេតុដូច្នេះហើយ ទម្រង់សហឧក្រិដ្ឋកម្មរួមទាំងនេះមិនអាចយកមកអនុវត្តនៅក្នុងសំណុំរឿងលេខ ០០២ ឡើយ។

## VI. មូលហេតុទី៤ នៃបណ្តឹងឧទ្ធរណ៍: ការខកខានក្នុងការដោះស្រាយលើទឡ្ហីករណ៍របស់មេធាវីការពារក្តី: JCE II និង JCE III មិនអាចអនុវត្តបានទេ

### ៦.១ សេចក្តីណែនាំ

38. នៅក្នុងសំណើស្តីពី JCE របស់ អៀង ធិរិទ្ធ ចែងថា[35] ពុំមានមូលដ្ឋានសម្រាប់ JCE III នៅកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ហើយថាមូលដ្ឋានសម្រាប់ JCE ទម្រង់ទី២ទៀតសោតគឺមានលក្ខណៈមិនច្បាស់លាស់ផងដែរ។ ចំនុចនេះក៏ត្រូវបានលើកឡើងនៅក្នុងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីលោក Kai Ambos[36]។ ប៉ុន្តែ ដីកាសម្រេចនេះខកខានមិនបានដោះស្រាយទឡ្ហីករណ៍របស់មេធាវីការពារក្តី ជាលទ្ធផលដីកាសម្រេចនេះផ្តល់មូលហេតុមិនគ្រប់គ្រាន់។

### ៦.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ

39. សេចក្តីសម្រេចនីមួយៗរបស់តុលាការគប្បីផ្តល់មូលហេតុក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ ដូចបានលើកឡើងនៅផ្នែក ៣.២ ខាងលើ ចំនុចនេះអាចចាត់ទុកថាជាគោលការណ៍ទូទៅនៃច្បាប់ ហើយចំនុចនេះក៏ត្រូវបានទទួលស្គាល់ដោយតុលាការអឺរ៉ុបនៅក្នុងរឿងក្តី *Hadjianastassiou តទល់ជាមួយប្រទេសក្រិច*[37] ដែរ។

---

[35] សំណើ JCE របស់ អៀង ធិរិទ្ធ ផ្នែក ៣.៤។

[36] សូមមើលសារណារបស់លោក Kai Ambos ផ្នែក II.3 និង II.4 ។

[37] *Hadjianastassiou តទល់ជាមួយប្រទេសក្រិច*, សេចក្តីសម្រេច, តុលាការអឺរ៉ុប, បណ្តឹងលេខ ១២៩៤៥/៨៧ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ កថាខណ្ឌទី៣៣។

40. កសចស មិនបានគោរពតាមគោលការណ៍ច្បាប់នេះទេ ដែលបង្កើតបានជាមូលដ្ឋានគតិយុត្តិធ្វើជាមូលហេតុនៃបណ្តឹងឧទ្ធរណ៍នេះ ។

## ៦.៣ សំណើ

41. នៅផ្នែក ៣.៤ នៃសំណើ JCE របស់ អៀង ធិរិទ្ធ មេធាវីការពារក្តីយល់ឃើញភាពអនុវត្តបាននៃ JCE ទម្រង់ទី២ នៅកម្ពុជាចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺមិនច្បាស់លាស់ និងការមិនមានអត្ថិភាពនៃ JCE ទម្រង់ទី៣ ។ ដោយឈរលើមូលដ្ឋាននេះហើយ ទាំងច្បាប់កម្ពុជា និងទម្លាប់អន្តរជាតិ គឺមានលក្ខណៈមិនច្បាស់លាស់ដូចគ្នា និងមិនកើតមានឡើងទៀតផង។ មេធាវីការពារក្តីយល់ឃើញទៀតថា ភាពមិនច្បាស់លាស់នេះត្រូវតែបានពន្យល់ក្នុងន័យផ្តល់ប្រយោជន៍ដល់ជនត្រូវចោទ ដោយអនុលោមទៅតាមគោលការណ៍វិមតិសង្ស័យ (principle of *in dubio pro reo)* ដែលចែងថា នៅពេលមានវិមតិសង្ស័យណាមួយនៅក្នុងការបកស្រាយបទបញ្ញត្តិច្បាប់នៅក្នុងច្បាប់ព្រហ្មទណ្ឌ ការបកស្រាយត្រូវតែជាប្រយោជន៍ដល់ជនជាប់ចោទ[38] ។

42. ខណៈដែលមានការសន្និដ្ឋានថា យុត្តិសាស្ត្រដែលលើកមកសំអាងដោយអង្គជំនុំជម្រះនៃតុលាការកំពូលនៅក្នុងរឿងក្តី *Tadic* ព្រឹត្តិការណ៍នានាដែលកើតឡើងពីមុនជាកម្មវត្ថុនៃស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញ កសចស យល់ឃើញថា JCE ទាំងបីទម្រង់អាចអនុវត្តបាននៅក្នុងដំណើរការនីតិវិធី ។ កសចស ខកខានមិនបានដោះស្រាយទឡ្ហីករណ៍របស់មេធាវីការពារក្តី ទាក់ទងទៅនឹងអវត្តមាននៃមូលដ្ឋានគតិយុត្តិនៅក្នុងបរិបទកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ។

## ៦.៤ សេចក្តីសន្និដ្ឋាន

43. ទាក់ទងនឹងចំនុចនេះ កសចស ខកខានមិនបានដោះស្រាយលើទឡ្ហីករណ៍ដែលលើកឡើងដោយមេធាវីការពារក្តី ។ អាស្រ័យហេតុនេះ ដីកានេះមិនបានផ្តល់មូលហេតុឲ្យបានគ្រប់គ្រាន់ ហើយត្រូវតែបដិសេធចោល ដោយផ្អែកលើចំនុចនេះ។

---

[38] រឿងក្តី *រដ្ឋអាជ្ញា តទល់ជាមួយ* *Tadic*, IT-94-1-A សាលដីកាលើពាក្យសុំរបស់ដើមបណ្តឹងឧទ្ធរណ៍ ស្នើសុំពន្យារពេលកំណត់ និងស្នើសុំដាក់បញ្ចូលភស្តុតាងបន្ថែម ចុះថ្ងៃទី១៥ ខែ តុលា ឆ្នាំ ១៩៩៨, កថាខណ្ឌទី៧៣។

## VII. មូលហេតុទី៥ នៃបណ្តឹងឧទ្ធរណ៍: កំហុសផ្នែកច្បាប់: ពុំមានយុត្តាធិការលើ JCE II និង JCE III- ពុំមានមូលដ្ឋានក្នុងច្បាប់ជាតិ

### ៧.១ សេចក្តីណែនាំ

44. ការដែលយល់ឃើញថា ទម្រង់ទី២ និងទម្រង់ទី៣ នៃសហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាន កសចស បានបកស្រាយដោយមិនត្រឹមត្រូវនូវច្បាប់គ្រប់គ្រងនីតិវិធីនៅ អវតក ។ ខណៈដែល JCE III មិនបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជានៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩, ហេតុដូច្នេះមូលដ្ឋានរបស់ JCE II មានលក្ខណៈមិនច្បាស់លាស់ ហើយត្រូវតែបានអនុវត្តក្នុងន័យជាប្រយោជន៍ដល់ជនត្រូវចោទ។ ដីកាសម្រេចនេះមិនទទួលស្គាល់ ឬបកស្រាយមិនត្រឹមត្រូវនូវធាតុផ្សំនេះ ហើយអាស្រ័យហេតុនេះ ដីកានេះត្រូវតែបដិសេធចោល ។

### ៧.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ

45. មេធាវីការពារក្តីយល់ឃើញថា ការសម្រេចរបស់ដីកាទាក់ទិនទៅនឹងភាពអនុវត្តបាននៃ JCE ទាំងបីទម្រង់ គឺសំអាងលើការបកស្រាយមិនត្រឹមត្រូវនូវច្បាប់ដែលគ្រប់គ្រងដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញ ។ ហេតុដូច្នេះ វាឋិតនៅក្រោមមូលហេតុទី១ សម្រាប់ច្រានចោលដីកាសម្រេចរបស់ កសចស ដូចដែលបានសម្រេចរួចមកហើយដោយអង្គបុរេជំនុំជម្រះ[39] ។

46. កសចស ខកខានមិនបានគោរពតាមគោលការណ៍ច្បាប់នេះ ដែលបង្កើតបានជាមូលដ្ឋានច្បាប់ធ្វើជាមូលហេតុនៃបណ្តឹងឧទ្ធរណ៍នេះ ។

### ៧.៣ សំណើ

47. មេធាវីការពារក្តីសូមស្នើថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី២ និងទម្រង់ទី៣ មិនអាចអនុវត្តបានទេចំពោះដំណើរការនីតិវិធីនេះ ។

48. លក្ខខណ្ឌតម្រូវមួយនៃលក្ខខណ្ឌតម្រូវនានា សម្រាប់ការអនុវត្តទម្រង់ណាមួយនៃការទទួលខុសត្រូវ គឺថាច្បាប់មានចែងពីទម្រង់នៃការទទួលខុសត្រូវនោះ "ដែលត្រូវតែបានអនុវត្តយ៉ាងទូលំទូលាយនៅពេលវេលាពាក់ព័ន្ធ ចំពោះជនដែលបានប្រព្រឹត្តអំពើបែបនោះ ហើយជននោះត្រូវតែអាចប្រមើល

---

[39] សាលដីកា SMD កថាខណ្ឌទី ២៦ ។

ឃើញជាមុនបានថា គាត់ត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើរបស់គាត់ ប្រសិនបើគាត់ត្រូវចាប់ខ្លួន[40] ។

49. មេធាវីការពារក្តីយល់ឃើញថា JCE III មិនមែនជាផ្នែកមួយនៃច្បាប់កម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ហើយថា ឋានៈរបស់ JCE II ទៀតសោតក៏មានលក្ខណៈមិនច្បាស់លាស់ផងដែរ ។

50. ដីកាសម្រេចនេះខកខានមិនបានដោះស្រាយទឡ្ហីករណ៍នេះ ដែលលើកឡើងដោយមេធាវីការពារក្តី។ ដូចដែលបានពន្យល់យ៉ាងត្រឹមត្រូវនៅក្នុងសារណារបស់លោក Kai Ambos មេធាវីការពារក្តីសូមទាញទឡ្ហីករណ៍ថា មានតែ JCE ទម្រង់ទី១ ទេ ត្រូវបានដាក់បញ្ចូលទាំងមិនច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលអាចអនុវត្តបាននៅពេលវេលាពាក់ព័ន្ធ ។ ទាក់ទងទៅនឹង JCE ទម្រង់ទី២វិញ លោក Kai Ambos ពន្យល់ថាវាមានលក្ខណៈមិនច្បាស់លាស់ថា តើក្រមព្រហ្មទណ្ឌកម្ពុជានាពេលនោះ ផ្តល់មូលដ្ឋានសម្រាប់ JCE ទម្រង់ទី២ ដែរ ឬយ៉ាងណានោះ ។ ភាពមានន័យមិនច្បាស់លាស់បែបនេះត្រូវតែបានពន្យល់ជាប្រយោជន៍ដល់ជាប់ចោទ ដោយប្រកាន់ភ្ជាប់ក្នុងចិត្តពីគោលការណ៍ *in dubio pro reo* នៃច្បាប់អន្តរជាតិ ។ ទាក់ទងទៅនឹង JCE ទម្រង់ទី៣ លោក Kai Ambos យល់ឃើញថា វាប្រាកដណាស់ថា JCE III នេះមិនបានបង្កើតជាផ្នែកមួយនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នោះទេ ហេតុដូច្នេះ វាមិនអាចអនុវត្តបានទេនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អវតក ។

## ៧.៤ សេចក្តីសន្និដ្ឋាន

51. ដីកាសម្រេចនេះត្រូវតែបដិសេធចោល ដោយសារតែមូលហេតុដែលផ្តល់ដោយ កសចស ផ្ទុយទៅនឹងច្បាប់ដែលតម្រូវថា ទម្រង់នៃការទទួលខុសត្រូវ បង្កើតជាផ្នែកមយនៃច្បាប់ជាតិនៅពេលវេលាពាក់ព័ន្ធ ។ ដីកាសម្រេចនេះរំលោភលើគោលការណ៍នេះ ហើយអាស្រ័យហេតុនេះ ខ្លឹមសារនៃដីកានេះត្រូវតែបដិសេធចោលផងដែរ។ ដោយលើមូលដ្ឋាននេះ អង្គបុរេជំនុំជម្រះត្រូវបានស្នើសុំឲ្យចេញសេចក្តីបង្គាប់ថា អវតក ពុំមានយុត្តាធិការលើការអនុវត្តសហឧក្រិដ្ឋកម្មរួម ទម្រង់ទី២ និងទម្រង់ទី៣ នោះទេ ។

[40] រឿងក្តី *រដ្ឋអាជ្ញា តទល់ជាមួយ Milutinovic* សេចក្តីសម្រេចលើពាក្យសុំរបស់ Draguljub Ojdanic ជំទាស់តវ៉ាទៅនឹងយុត្តាធិការ-សហកម្មឧក្រិដ្ឋកម្មរួម, សំណុំរឿង IT-99-37-AR2 កថាខណ្ឌទី២១, ចុះថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០០៣ ។

## VIII. មូលហេតុទី៦ នៃបណ្តឹងឧទ្ធរណ៍: ការខកខានមិនបានវិភាគលើទម្លាប់អន្តរជាតិ ដែលជាមូលដ្ឋានសម្រាប់ JCE

### ៨.១ សេចក្តីផ្តើម

52. ដីកាសម្រេចខកខានមិនបានសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទាំងបីជាផ្នែកមួយនៃទម្លាប់អន្តរជាតិនៅពេលវេលាពាក់ព័ន្ធ។ នេះគឺជាលក្ខខណ្ឌតម្រូវមួយក្នុងការយល់ឃើញថាសហឧក្រិដ្ឋកម្មរួម ឬទម្រង់នៃការទទួលខុសត្រូវណាមួយចំពោះបញ្ហានោះ អាចអនុវត្តបាន ។ ការខកខានបែបនេះ កសចស មិនបានផ្តល់មូលហេតុឲ្យបានគ្រប់គ្រាន់ចំពោះសេចក្តីសម្រេចរបស់ខ្លួន ហើយបានធ្វើឲ្យមានកំហុសផ្នែកច្បាប់ទៀតផង។ ដោយមូលហេតុនេះ ដីកាសម្រេចនេះត្រូវតែបដិសេធចោល ។

### ៨.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ

53. បទដ្ឋានច្បាប់សម្រាប់ធ្វើជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ គឺការរួមបញ្ចូលគ្នាទាំងការផ្តល់មូលហេតុមិនគ្រប់គ្រាន់ ដែលជាមូលដ្ឋានផ្នែកច្បាប់ដែលត្រូវបានលើកឡើងនៅផ្នែក ៣.២ ខាងលើ និងការបកស្រាយមិនត្រឹមត្រូវនូវច្បាប់មួយដែលគ្រប់គ្រងដំណើរការនីតិវិធីនៅ អវតក ដែលឋិតនៅក្រោមមូលហេតុទី១ សម្រាប់ការបដិសេធចោលដីកាសម្រេចរបស់ កសចស ដូចដែលត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះរួចមកហើយ[41]។

54. កសចស ខកខានមិនបានគោរពគោលការណ៍ច្បាប់នេះ ដែលបង្កើតបានជាមូលដ្ឋានច្បាប់ដើម្បីធ្វើជាមូលហេតុនៃបណ្តឹងឧទ្ធរណ៍នេះ ។

### ៨.៣ សំណើ

55. នៅក្នុងដីកាសម្រេច កសចស ខកខានមិនបានស្វែងយល់ទម្លាប់អន្តរជាតិ ដែលជាមូលដ្ឋានសម្រាប់អនុវត្តសហឧក្រិដ្ឋកម្មរួម នោះទេ។ មានការយោងតែមួយគត់នៅក្នុងដីកាសម្រេចនេះចំពោះទម្លាប់អន្តរជាតិ គឺនៅក្នុងកថាខណ្ឌទី២១ ដែលចែងថា "សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការអនុវត្តទម្លាប់អន្តរជាតិនៅ អវតក គឺជាការសន្និដ្ឋានដែលទាញចេញអំពីហេតុដែលថា អវតក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ ដែលអនុវត្តច្បាប់អន្តរជាតិ[42]។ គ្មានអ្វីទាំងអស់ ក្រៅតែពីការ

[41] សាលដីកា SMD កថាខណ្ឌទី ២៦ ។

[42] Footnote លុបចោល ។

យល់ឃើញថា អវតក ជាតុលាការអន្តរជាតិមួយ ហើយអាចអនុវត្តច្បាប់អន្តរជាតិ ។ កសចស ខកខានមិនបានពន្យល់បន្ថែមទៀតថា តើគេមានមូលដ្ឋានសម្រាប់ JCE នៅក្នុងទម្លាប់អន្តរជាតិដែរ ឬអត់ ថាតើវិធាននៃទម្លាប់អន្តរជាតិដែលសន្មតនេះ ក៏អាចអនុវត្តបាននៅកម្ពុជា និងថាតើវិធានដែលសន្មតនេះ អាចអនុវត្តបាននៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរ ឬយ៉ាង។ កសចស ខកខានមិនបានគូសបញ្ជាក់ពីជំហានចាំបាច់នេះនៅក្នុងការវិភាគពីភាពអាចអនុវត្តបានរបស់ JCE នៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្នប្រឆាំងនឹងជនត្រូវចោទ ។

56. កសចស បញ្ជាក់បន្ថែមទៀតនៅក្នុងកថាខណ្ឌទី២១ ថា:

> ដោយយោងទៅលើចរិតលក្ខណៈអន្តរជាតិរបស់ អវតក នេះ និងដោយពិចារណាឃើញថា យុត្តិសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីវាយតំលៃអំពី JCE ត្រូវបានតាក់តែងឡើងនៅមុនពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរនៅមុខ អវតក[៣៩] កើតមានឡើង សហចៅក្រមស៊ើបអង្កេតយល់ឃើញថា JCE អាចអនុវត្តបានដោយផ្អែកលើមូលដ្ឋានដែលកំណត់នៅក្នុងច្បាប់អន្តរជាតិដូចដែល បានលើកឡើងនៅក្នុងកថាខណ្ឌទី១៤ ដល់ ១៧ រួមទាំង កំណត់យោងចុងទំព័រ ដែលទាក់ទងនឹងការវាយតំលៃជាអត្តនោម័តនៃផលវិបាកជាលក្ខណៈអន្តរជាតិ និងអាចព្យាករជាមុន[៤០]។

---

អក្សរក្នុងលេខយោងទី៣៩ *IT-94-1-A* សាលដីកា កថាខណ្ឌទី១៨៥ និងបន្តបន្ទាប់ ។

អក្សរក្នុងលេខយោងទី៤០ *IT-98-30/1-A, Kvocka* និងអ្នកផ្សេងទៀត, កថាខណ្ឌទី៨៦ នៃសាលដីកា " [...] អ្នកចូលរួមម្នាក់អាចទទួលខុសត្រូវចំពោះបទល្មើស តែក្នុងករណីដែលរដ្ឋអាជ្ញាបង្ហាញថា ជនជាប់ចោទយល់ដឹងយ៉ាងច្បាស់លាស់ថា បទល្មើសនោះជាផលវិបាកជាធម្មជាតិ និងអាចដឹងជាមុន" ។ (បញ្ជាក់បន្ថែម) ។

57. បន្ទាប់ពីបានថ្លែងបញ្ជាក់ថា ទម្លាប់អន្តរជាតិមានតួនាទីនៅអង្គជំនុំជម្រះវិសាមញ្ញ ក្រោយមក កសចស បានយោងរឿងក្តី Tadic ដោយសន្និដ្ឋានថា យុត្តិសាស្ត្រដែលបានយោងនៅក្នុងរឿងក្តី Tadic ត្រូវបានតាក់តែងឡើងនៅមុនតុលាការនេះ ហើយបានសន្និដ្ឋានបន្ថែមទៀតថា អាស្រ័យហេតុនេះ JCE អាចអនុវត្តបាន ។ ពុំមានការវិភាគលើរឿងក្តីជាក់លាក់បែបនេះទេ ហើយក៏ពុំមានការជូនដំណឹងចំពោះការដែលថា យុត្តិសាស្ត្រដែលលើកឡើងនៅក្នុងរឿងក្តី Tadic គឺឋិតនៅឆ្ងាញពីតំបន់អាស៊ីអគ្នេយ៍ គឺនៅឆ្ងាញពីប្រទេសកម្ពុជា។ ពុំមានការបញ្ជាក់ថា យុត្តិសាស្ត្រនៅទីនោះគឺយោងទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅប្រទេសអាឡឺម៉ង់ក្នុងសម័យសង្គ្រាមលោកលើកទី២ ។ ពុំមានការប៉ុនប៉ងបង្ហាញពីភាពពាក់ព័ន្ធរបស់យុត្តិសាស្ត្រចំពោះនីតិវិធីបច្ចុប្បន្នដែរ ។ ការគ្រាន់តែ

00432558



យោងរឿងក្តី Tadic គឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញថា JCE អាចអនុវត្តបាននៅក្នុងដំណើរនីតិវិធីបច្ចុប្បន្ននេះទេ ។

58. កថាខណ្ឌទី ២០៥-២១៨ នៃសាលដីការឿងក្តី Tadic មានខ្លឹមសារ និងសេចក្តីពន្យល់អំពីមូលដ្ឋាននៃទម្លាប់អន្តរជាតិសម្រាប់ការអនុវត្ត JCE III ក្នុងបរិបទជាក់លាក់នៃករណីនេះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY)។ វាជាមូលដ្ឋានមួយដែលមិនគ្រប់គ្រាន់សម្រាប់ការសម្រេចថា វាអាចអនុវត្តបានតាមការកែប្រែចាំបាច់ *mutatis mutandis* នៅក្នុងដំណើរការនីតិវិធីនៅ អវតក ។

## ៨.៤ សេចក្តីសន្និដ្ឋាន

59. ដីកានេះបានខកខានមិនស្វែងយល់ពីមូលដ្ឋាននៃទម្លាប់អន្តរជាតិសម្រាប់អនុវត្តសហឧក្រិដ្ឋកម្មរួមនៅកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ។ មេធាវីការពារក្តីបានលើកអំណះអំណាងដាច់ដោយឡែក ហើយបានធ្វើរួចមកហើយនៅក្នុងសំណើ JCE របស់ អៀង ធីរិទ្ធ ថាមូលដ្ឋាននេះពិតជាមិនកើតមាននោះទេ ប៉ុន្តែ មូលហេតុបណ្តឹងឧទ្ធរណ៍នេះផ្តោតទៅលើអវត្តមាននៃការពិភាក្សានៅក្នុងដីកាសម្រេចនេះ ។ ការខកខានមិនបានស្វែងយល់ពីទម្លាប់អន្តរជាតិសម្រាប់អនុវត្ត JCE នោះដីកានេះត្រូវតែបដិសេធចោល ។

## IX. មូលហេតុទី៧ នៃបណ្តឹងឧទ្ធរណ៍- អវត្តមាននៃមូលដ្ឋាននៃទម្លាប់អន្តរជាតិសម្រាប់ JCE

## ៩.១ សេចក្តីណែនាំ

60. បន្ថែមពីលើការជំទាស់ទៅនឹងដីកាសម្រេចដោយផ្តល់មូលហេតុមិនគ្រប់គ្រាន់ ពីព្រោះតែការខកខានមិនបានបញ្ជាក់ថា តើ JCE ត្រូវបានដាក់បញ្ចូលទៅក្នុងវិធាននៃទម្លាប់អន្តរជាតិដែលអាចអនុវត្តបាននៅកម្ពុជារវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរ ឬយ៉ាងណា មេធាវីការពារក្តីក៏ជំទាស់ផងដែរទៅនឹងការសន្និដ្ឋានដែលថា JCE ទាំងបីទម្រង់បង្កើតបានជាផ្នែកមួយនៃទម្លាប់អន្តរជាតិនៅពេលនោះ ។ ខណៈដែល កសចស រំលងជំហាននេះនៅក្នុងការវិភាគរបស់ខ្លួន ការយល់ឃើញបែបនេះ គឺចាំបាច់ដើម្បីសម្រេចពីភាពអាចអនុវត្តបាននៃ JCE ហើយអាស្រ័យហេតុនេះ កសចស បានធ្វើសេចក្តីសម្រេចនេះដោយភាន់ច្រឡំ ប៉ុន្តែ ចែងមិនឲ្យច្បាស់លាស់ ហើយមេធាវីការពារក្តីត្រូវតែលើកបញ្ហានេះឡើង ។

### ៩.២ បទដ្ឋានច្បាប់ពាក់ព័ន្ធ

61. ដីកាសម្រេចលើភាពអាចអនុវត្តបាននៃ JCE ទាំងបីទម្រង់ គឺអាស្រ័យលើការបកស្រាយមិនត្រឹមត្រូវនូវច្បាប់ដែលគ្រប់គ្រងដំណើរការនីតិវិធីនៅ អវតក ។ អាស្រ័យហេតុនេះ វាឋិតនៅក្រោមមូលហេតុទីមួយសម្រាប់ការបដិសេធចោលដីការបស់ កសចស ដូចដែលត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះរួចមកហើយ[43]។

62. កសចស ខកខានមិនបានគោរពតាមគោលការណ៍នៃច្បាប់ ដែលបង្កើតបានជាមូលដ្ឋានច្បាប់សម្រាប់ធ្វើជាមូលហេតុនៃបណ្តឹងឧទ្ធរណ៍នេះ ។

### ៩.៣ សំណើ

63. អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿង *Tadic* ចាត់ទុកថាវិធាននៃទម្លាប់អន្តរជាតិ អាចយល់បានថាផ្តល់មូលដ្ឋានសម្រាប់អនុវត្តសហឧក្រិដ្ឋកម្មរួម[44] ដែលអាចអនុវត្តបានក្នុងអំឡុងពេលពាក់ព័ន្ធនៃជម្លោះនៅអតីតយូហ្គោស្លាវី និងនៅតំបន់នោះនៃពិភពលោក ។ នៅក្នុងការពិភាក្សា អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY សំអាងលើយុត្តិសាស្ត្រជាក់លាក់មួយចំនួនដែលអាចអនុវត្តបានចំពោះនីតិវិធីនៅ ICTY ។ ប៉ុន្តែ យុត្តិសាស្ត្រនេះមិនអាចអនុវត្តចំពោះនីតិវិធីនៅ អវតក បានទេ ។

64. ជាបឋម វាជាការចម្រូងចម្រាស់មួយថា តើការសន្និដ្ឋាននៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿង *Tadic* ទាក់ទងទៅនឹងមូលដ្ឋានទម្លាប់អន្តរជាតិរបស់ JCE ស្របតាមគោលការណ៍នីត្យានុកូលភាព[45] ដែរ ឬយ៉ាងណា ។ មេធាវីការពារក្តីយល់ឃើញថា បើទោះបី ICTY មានយុត្តាធិការលើ JCE ក៏ពិតមែន ប៉ុន្តែ JCE មិនអាចអនុវត្តតាមការកែប្រែចាំបាច់ (*mutatis mutandis*) នៅក្រោមយុត្តាធិការរបស់ អវតក បានដែរ ។

---

[43] សាលដីកា SMD កថាខណ្ឌទី ២៦ ។

[44] រឿងក្តី *រដ្ឋអាជ្ញា តទល់ជាមួយ* . *Dusko Tadic*, IT-94-1-A កថាខណ្ឌទី ១៩៤ នៃសាលដីកាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩, សំណុំរឿង IT-94-1-A, ។

[45] A.M. Danner & J.S. Martinez, 'Guilty Associations: សហឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាមេបញ្ជាការ និង ការវិវឌ្ឍន៍នៃនីតិព្រហ្មទណ្ឌអន្តរជាតិ" ខែ មីនា ឆ្នាំ២០០៤ ទំព័រ ៣១ ។

65. អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿង *Tadic* យោងទៅលើមូលដ្ឋានទម្លាប់អន្តរជាតិនៃសហឧក្រិដ្ឋកម្មរួម ដែលភាគច្រើនពឹងផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការយោធាក្រោយសង្គ្រាមលោកលើកទី២[46] ដែលពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅលើទឹកដីអឺរ៉ុប ។ អនុលោមទៅតាម Danner និង Martinez "រឿងក្តីដែលលើកមកសំអាងនៅក្នុងរឿងក្តី *Tadic* មិនគាំទ្រដល់ JCE ទម្រង់លាតសន្ធឹងនោះទេ ជាពិសេស ទម្រង់ពន្លាតនៃការទទួលខុសត្រូវ"[47] ។

66. យុត្តិសាស្ត្រនេះមិនអាចផ្ទេរមកដែនដីអាស៊ីបានទេ ជាពិសេស ដោយសារតែ JCE III រកមិនបាននូវមូលដ្ឋាននៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[48]។ JCE III មិនត្រូវបានបញ្ចូលនៅក្នុងច្បាប់កម្ពុជា ហើយរឿងក្តី *Tadic* យោងទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅទ្វីបអឺរ៉ុប និងពាក់ព័ន្ធជាមួយតុលាការយោធាក្រោយសង្គ្រាមលោកលើកទី២ ដែលមានមូលដ្ឋាននៅអាមេរិកខាងជើង និងនៅទ្វីបអឺរ៉ុប ហើយលើកឡើងពីប្រព័ន្ធច្បាប់របស់ប្រទេសអូស្ត្រាលី និងហ្សែមប៊ី ។ មេធាវីការពារយល់ឃើញថា យុត្តិសាស្ត្រដែលផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿង *Tadic* មិនអាចបង្កើតបានជាផ្នែកមួយនៃទម្លាប់អន្តរជាតិ ដែលអាចអនុវត្តនៅក្នុងបរិបទពិសេសនៅកម្ពុជាបានទេ

67. អង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងរឿង *Milutinovic* យល់ឃើញបន្តទៀតថា ក្រៅពីមានមូលដ្ឋាននៅក្នុងច្បាប់ជាតិ ទម្រង់នៃការទទួលខុសត្រូវ ត្រូវការមូលដ្ឋាននៅក្នុងទម្លាប់អន្តរជាតិផងដែរ ។ ច្បាប់ជាតិតែឯង មិនគ្រប់គ្រាន់នោះទេ។ អង្គជំនុំជម្រះតុលាការកំពូល ICTY សម្រេច:

> បើទោះបីច្បាប់ជាតិ [ជាពិសេសច្បាប់ប្រទេសរបស់ជនជាប់ចោទសាម៉ី] អាចថែងពីការជូនដំណឹងចំពោះអំពើដែលគាត់បានប្រព្រឹត្តថា ជាបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ច្បាប់អន្តរជាតិ

---

[46] .M. Danner & J.S. Martinez, 'Guilty Associations: សហឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាមេបញ្ជាការ និង ការវិវឌ្ឍន៍នៃនីតិព្រហ្មទណ្ឌអន្តរជាតិ" ខែ មីនា ឆ្នាំ២០០៤ ទំព័រ ២៨ ។

[47] M. Danner & J.S. Martinez, 'Guilty Associations: សហឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាមេបញ្ជាការ និង ការវិវឌ្ឍន៍នៃនីតិព្រហ្មទណ្ឌអន្តរជាតិ" ខែ មីនា ឆ្នាំ២០០៤ ទំព័រ ៣៨ ។

[48] សូមមើលលក្ខខណ្ឌគម្រូវនេះ, រឿងក្តី*រដ្ឋអាជ្ញា តទល់ជាមួយ Milutinovic* កថាខណ្ឌទី៤១ នៃសេចក្តីសម្រេចលើញត្តិរបស់ Dragoljub Ojdanic ជំទាស់តវ៉ានឹងយុត្តាធិការ: សហឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ IT-99-37-AR2, ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ។

ហើយ ច្បាប់មិនចាំបាច់ជូនដំណឹងឲ្យបានគ្រប់គ្រាន់នោះទេ[49] ។

68. តាមពិត កសព ក៏បានយល់ព្រមនៅក្នុងចម្លើយតបរបស់ខ្លួនចំពោះសំណើ JCE របស់ អៀង សារី ដែរ៖

> ប៉ុន្តែ [ នៅក្នុងការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី Tadic ] ទៅលើប្រព័ន្ធច្បាប់ជាតិនានាដែលអនុវត្តទម្រង់នៃការទទួលខុសត្រូវ"គោលបំណងរួម" សង្កត់ធ្ងន់ថា"ការយោងច្បាប់ និងយុត្តិសាស្ត្រជាតិ បំរើតែដើម្បីបង្ហាញឲ្យឃើញថា សញ្ញាណនៃគោលបំណងរួមដែលប្រកាន់ភ្ជាប់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលទទួលបានការគាំទ្រពីប្រព័ន្ធច្បាប់របស់ប្រទេសជាច្រើន" តែប៉ុណ្ណោះ ប៉ុន្តែវាមិនគាំទ្រចំពោះការយល់ឃើញថា ទ្រឹស្តីមាននៅក្នុងទម្លាប់អន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Milutinovic* បានសម្រេចនៅពេលក្រោយមកទៀតថា ទទួលស្គាល់នូវការទទួលខុសត្រូវប្រភេទ JCE នៅក្នុងច្បាប់ជាតិជួយគាំទ្រដល់យល់ឃើញថា ជនជាប់ចោទត្រូវបានជូនដំណឹងគ្រប់គ្រាន់ថា គាត់ត្រូវផ្តន្ទាទោសក្រោមទម្រង់នៃការទទួលខុសត្រូវនេះ[50] ។

69. នៅក្នុងរឿងក្តីនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ក្រៅពីច្បាប់ជាតិ មានមូលដ្ឋានគ្រប់គ្រាន់នៅក្នុងទម្លាប់អន្តរជាតិ ដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តីនៅក្នុងករណីនេះ (សូមមើលមូលហេតុទី៧ នៃបណ្តឹងឧទ្ធរណ៍ខាងក្រោម)។

70. អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadic* ជាញឹកញយបានពិចារណាអំពីមូលដ្ឋាន JCE នៅក្នុងទម្លាប់អន្តរជាតិ ក្រោយពីបានវិភាគយុត្តិសាស្ត្រជាតិពីប្រទេសនានា ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ ដូចខាងក្រោម៖

> សូមគូសបញ្ជាក់ថា ការយោងច្បាប់ និងយុត្តិសាស្ត្រជាតិ បម្រើតែ ដើម្បីបង្ហាញឲ្យឃើញថា សញ្ញាណនៃគោលបំណងរួមដែលប្រកាន់ភ្ជាប់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលទទួលបានការគាំទ្រពីប្រព័ន្ធច្បាប់របស់ប្រទេសជាច្រើន" តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ នៅក្នុងប្រធានបទដែល

---

[49] រឿងក្តី *រដ្ឋអាជ្ញា តទល់ជាមួយ Milutinovic* កថាខណ្ឌទី៤១ នៃសេចក្តីសម្រេចលើញាតិរបស់ Draguljub Ojdanic ជំទាស់តវ៉ានឹងយុត្តាធិការៈ សហឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ IT-99-37-AR2, ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ។

[50] កថាខណ្ឌទី២៨ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះញាតិរបស់ អៀង សារី ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០០៨, ឯកសារលេខ D97/2 (អក្សរក្នុងលេខយោងលុបចោល)។

កំពង់ពិភាក្សានេះ ច្បាប់ និងយុត្តិសាស្ត្រជាតិមិនអាចប្រើប្រាស់ជាប្រភពនៃគោលការណ៍ ឬវិធាន អន្តរជាតិនោះទេ ក្រោមទ្រឹស្តីទូទៅនៃច្បាប់ ដែលត្រូវបានទទួលស្គាល់ដោយប្រទេសជាតិជាច្រើន នៅលើពិភពលោក: ដើម្បីឱ្យច្បាប់ និងយុត្តិសាស្ត្រជាតិនេះ ត្រូវបានទទួលយក វាចាំបាច់បង្ហាញ ឱ្យឃើញថា ប្រទេសភាគច្រើន បើមិនមែនទាំងអស់ អនុម័តយកសញ្ញាណដូចគ្នាចំពោះគោល បំណងរួម ។ បន្ថែមពីលើនេះ គេចាំបាច់បង្ហាញឱ្យឃើញថា ប្រព័ន្ធច្បាប់សំខាន់ៗនៅលើពិភព លោកយើងនេះអនុម័តយកមធ្យោបាយដូចគ្នាចំពោះសញ្ញាណនេះ។ ការស្ទង់មតិខ្លីខាងលើបង្ហាញ ឱ្យឃើញថា វាមិនអាចធ្វើទៅរួចបាននោះទេ។ នៅក្នុងករណីនេះ គេមិនអាចយោងច្បាប់ជាតិ បានទេ ហើយទំហំនិងនិយមន័យនៅក្នុងវាក្យសព្ទទូទៅនៃរបាយការណ៍របស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ ចែងថា “មានការលើកឡើងថា តុលាការអន្តរជាតិត្រូវអនុវត្ត*ច្បាប់ជាតិ* ដោយសារតែបច្ចុប្បន្ននេះ ច្បាប់ជាតិ *បានដាក់បញ្ចូល*នៅក្នុងច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ” រួចហើយ ។ ប្រធានបទដែលយើងកំពង់ពិភាក្សានេះ ច្បាប់ជាតិមិនបានចាប់កំណើតចេញពីការ អនុវត្តច្បាប់អន្តរជាតិនោះទេ តែច្បាប់ជាតិដើរទន្ទឹមគ្នាជាមួយច្បាប់អន្តរជាតិ[51] ។

71. ចំនុចនេះបញ្ជាក់ន័យថា ពុំមានច្បាប់ជាតិអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវនេះឡើយ ហើយ ច្បាប់អន្តរជាតិមិនអាចបំពេញចំនុចចន្លោះប្រហោងនេះបានដែរ។ ជាផលវិបាក ទម្រង់នៃការទទួល ខុសត្រូវនេះមិនអាចអនុវត្តបានទេ។ កសចស ពិតជាមិនអើពើចំពោះទឡ្ហីករណ៍នេះនៅក្នុងដីកា សម្រេចរបស់ខ្លួន ។

72. ដោយសារតែមូលដ្ឋាន JCE ក្នុងទម្លាប់អន្តរជាតិសម្រាប់ ICTY មានភាពចម្រូងចម្រាស់ខ្លាំង[52] វាពិតជាមិនអាចផ្ទេរមកប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧០ បាននោះទេ នៅពេលដែលគ្មានមូលដ្ឋានណា

---

[51] សូមមើលការព្យាយាមពន្យល់មូលហេតុក្រោយការលើកឡើងនេះ៖ M. Sassoli & L.M. Olson, “សាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល ICTY លើអង្គសេចក្តីក្នុងរឿងក្តី Tadic” ទស្សនាវដ្តីកាកបាទក្រហម លេខ ៨៣៩ ទំព័រ ៧ ។

[52] សូមមើលឧទាហរណ៍ M. Sassoli & L.M. Olson, “សាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល ICTY លើអង្គសេចក្តីក្នុងរឿងក្តី Tadic” ទស្សនាវដ្តីកាកបាទក្រហម លេខ ៨៣៩ ទំព័រ៧ អ្នកនិពន្ធលើកឡើងពីភាពចម្រូងចម្រាស់ ទាក់ទងនឹងមូលហេតុដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី Tadic រៀបរាប់យុត្តិសាស្ត្ររបស់អ៊ីតាលី ដើម្បីគាំទ្រដល់ទ្រឹស្តី JCE ហើយ មិនអើពើយុត្តិសាស្ត្ររបស់ប្រទេសហូឡង់ និងប្រទេសអាឡឺម៉ង់ ដែលមិនគាំទ្រដល់ទ្រឹស្តី JCE ។ សូមមើលបន្ថែមទៀត .M. Danner & J.S. Martinez, ‘Guilty Associations: សហឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាមេបញ្ជាការ និង ការវិវឌ្ឍន៍នៃនីតិព្រហ្មទណ្ឌអន្តរជាតិ” ខែ មីនា ឆ្នាំ២០០៤ ទំព័រ ២៨ ។

មួយនៅក្នុងយុត្តិសាស្ត្ររបស់ប្រព័ន្ធច្បាប់អាស៊ីអាគ្នេយ៍ កុំថាឡើយប្រព័ន្ធច្បាប់របស់កម្ពុជានោះ។

73. លក្ខខណ្ឌតម្រូវចាំបាច់ចំនួនបីក្នុងចំណោមលក្ខខណ្ឌតម្រូវចំនួនបួន សម្រាប់អនុវត្តទម្រង់នៃការទទួលខុសត្រូវ ដូចដែលបានតាក់តែងនៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់ជាមួយ Milutinovic* មិនត្រូវបានបំពេញ ។ លក្ខខណ្ឌតម្រូវទាំងនោះមានដូចជា៖

(ក) ទម្រង់នៃការទទួលខុសត្រូវ ត្រូវតែមាននៅក្នុងទម្លាប់អន្តរជាតិ ។

(ខ) ទម្រង់នៃការទទួលខុសត្រូវជាក់លាក់នោះ ត្រូវតែអាចយល់បាន និងអាចប្រមើលឃើញជាមុននៅពេលវេលាពាក់ព័ន្ធ និង

(គ) ជននោះត្រូវតែអាចប្រមើលឃើញជាមុនថា គាត់នឹងត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើចាប់ខ្លួន។ គេមិនអាចបង្ហាញការចោទប្រកាន់ថា ជនជាប់ចោទអាចប្រមើលឃើញជាមុននូវការទទួលខុសត្រូវទម្រង់ JCE III នៅកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បានទេ[53]។

74. អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadic* យល់ឃើញថា សន្ធិសញ្ញាអន្តរជាតិចំនួនពីរ (២) ផ្តល់មូលដ្ឋានសម្រាប់ JCE III ជាពិសេស អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការដាក់គ្រាប់បែកភេរវកម្មឆ្នាំ១៩៩៧ (the International Convention for the Suppression of Terrorist Bombing of 1997) និងលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ ១៩៩៨[54] ដែលជាក់ស្តែង អនុសញ្ញាទាំងពីរនេះកើតឡើងនៅក្រោយព្រឹត្តិការណ៍ដែលជាកម្មវត្ថុនៃការស៊ើបសួររបស់តុលាការនេះ។ ដូចដែលបង្ហាញដោយលោក Kai Ambos រួចមកហើយ JCE ទម្រង់ទី៣ ពុំមានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជា ដែលអាចអនុវត្តនៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ហើយមូលដ្ឋានសម្រាប់ JCE ទម្រង់ទី២ទៀតសោត គឺមានលក្ខណៈមិនច្បាស់លាស់ដែរ[55]។ ហេតុដូច្នេះ គេមិនអាចនិយាយថា JCE II និង JCE III អាចអនុវត្តបាននៅតុលាការនេះ ហើយការបកស្រាយផ្សេងពីនេះ នឹងផ្ទុយពីច្បាប់អន្តរជាតិ។ ការបកស្រាយដែលផ្តល់ដោយដីកាសម្រេចនេះ គឺរំលោភច្បាប់អន្តរជាតិ ហើយដីកានេះត្រូវតែ

---

[53] រឿងក្តី *រដ្ឋអាជ្ញា តទល់ជាមួយ Milutinovic* កថាខណ្ឌទី២១ នៃសេចក្តីសម្រេចលើញត្តិរបស់ Draguljub Ojdanic ជំទាស់តវ៉ានឹងយុត្តាធិការ: សហឧក្រិដ្ឋកម្មរួម, សំណុំរឿងលេខ IT-99-37-AR2, ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ។

[54] កថាខណ្ឌទី ២២១-២២២ នៃសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី Tadic ។

[55] សារណារបស់លោក Kai Ambos ផ្នែក II.4 ។

00432564



បដិសេធចោល ។

## ៩.៤ សេចក្តីសន្និដ្ឋាន

75. អាស្រ័យហេតុនេះ មេធាវីការពារក្តីយល់ឃើញថា មូលដ្ឋានក្នុងទម្លាប់អន្តរជាតិសម្រាប់ JCE II និង JCE III ដែលអាចអនុវត្តបាននៅ ICTY គឺមិនស្របគ្នាជាមួយយុត្តាធិការរបស់ អវតក ។ ដីកានេះខកខានមិនបានដោះស្រាយលើបញ្ហានេះ ហេតុដូច្នេះ ដីកានេះត្រូវតែបដិសេធចោល ។ ជំនួសមកវិញ អង្គបុរេជំនុំជម្រះត្រូវបានស្នើសុំឲ្យយល់ថា JCE ទម្រង់ទី២ និង JCE ទម្រង់ទី៣ មិនអាចអនុវត្តបានចំពោះដំណើរការនីតិវិធីរបស់ អវតក ទេ ដោយសារតែពុំមានមូលដ្ឋាននៅក្នុងទម្លាប់អន្តរជាតិ ។

## X. សំណើសុំសវនាការដេញដោលផ្ទាល់មាត់

76. ពិចារណាលើភាពស្មុគស្រាញរបស់រឿងក្តីបច្ចុប្បន្ន ព្រមទាំងសារៈសំខាន់របស់វា មិនមែនតែសម្រាប់អ្នកចូលរួមនៅក្នុងសំណុំរឿង០០២ ប៉ុណ្ណោះទេ ប៉ុន្តែ សម្រាប់ជំនឿទុកចិត្តរបស់ អវតក និង សង្គមអ្នកច្បាប់អន្តរជាតិ មេធាវីការពារក្តីស្នើសុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់។ បញ្ហាណាមួយដែលកើតចេញពីភាពស្មុគស្រាញនេះ អាចលើកឡើងដោយផ្ទាល់មាត់បាន ។

77. នៅក្នុងសេចក្តី "សម្រេចលើសំណើសុំសវនាការដេញដោលផ្ទាល់មាត់" ក្នុងបណ្តឹងឧទ្ធរណ៍ PTC-24 និង PTC-25 អង្គបុរេជំនុំជម្រះបានយល់ឃើញថា ជាវិធានទូទៅអង្គបុរេជំនុំជម្រះមិនអាចចាត់ឲ្យមានសវនាការដេញដោលជាសារណៈទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរបានទេ ដោយសារតែចរិតសម្ងាត់របស់វា។ មេធាវីការពារយល់ឃើញថា ការពិចារណានេះគឺមិនពាក់ព័ន្ធទៅនឹងបញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ដែលតាមចរិតលក្ខណៈរបស់វាត្រូវតែបានដោះស្រាយឲ្យមានតម្លាភាព ដោយសារតែបញ្ហានេះមិនមែនជាកម្មវត្ថុនៃការស៊ើបសួរឡើយ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីយល់ឃើញថា ចរិតលក្ខណៈនៃអំណះអំណាងគប្បីឲ្យមានសវនាការដេញដោលជាសាធារណៈ ហើយវាអាចជួយដល់ចៅក្រមក្នុងការដោះស្រាយជាមួយបញ្ហាដែលអាចកើតឡើង និងផ្តល់នូវតម្លាភាពកាន់តែច្រើនដល់សាធារណជន និងសហគមន៍អន្តរជាតិអំពីដំណើរការនីតិវិធីដ៏សំខាន់នេះ ។

## XI. សំណូមពរ

78. សម្រាប់ហេតុផលដែលបានលើកឡើងនៅទីនេះ មេធាវីការពារក្ដីស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលដីកានេះ និងជំនួសមកវិញនូវការយល់ឃើញថា៖

(i) ជាបឋម អវតក ពុំមានយុត្តាធិការទៅលើ JCE ជាទម្រង់នៃការទទួលខុសត្រូវ ។

(ii) មួយវិញទៀត អវតក ពុំមានយុត្តាធិការអនុវត្ត JCE ទម្រង់ទី២ និងទម្រង់ទី៣ ដែរ ។

(iii) ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាបានសម្អាងទឡ្ហីករណ៍មិនគ្រប់គ្រាន់ចំពោះ JCE ទម្រង់ទី១ និង JCE ទម្រង់ទី៣ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលអាចអនុវត្តនៅក្នុងសំណុំរឿង០០២ ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ១៨ មករា ឆ្នាំ ២០១០ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |